ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀងស្តីពីវិធានការរដ្ឋម្ចាស់កំពង់ផែ ដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានការអនុញ្ញាត និងគ្មានរបាយការណ៍



ខែមីនា ឆ្នាំ២០២០

# មាតិកា


បុព្វកថា.................................................1
ផ្នែកទី ១. បទប្បញ្ញត្តិទូទៅ.................................................3
មាត្រា ១. ការប្រើវាក្យស័ព្ទ.................................................3
មាត្រា ២. គោលបំណង.................................................3
មាត្រា ៣. ការអនុវត្ត.................................................3
មាត្រា ៤. ទំនាក់ទំនងជាមួយច្បាប់ និងលិខិតុបករណ៍អន្តរជាតិដទៃទៀត.................................................4
មាត្រា ៥. សមាហរណកម្ម និងការសម្របសម្រួលថ្នាក់ជាតិ.................................................5
មាត្រា ៦. កិច្ចសហប្រតិបត្តិការ និងការផ្លាស់ប្តូរព័ត៌មាន.................................................5
ផ្នែកទី ២. ការចូលចតនៅកំពង់ផែ.................................................5
មាត្រា ៧. ការកំណត់កំពង់ផែ.................................................5
មាត្រា ៨. សំណើសុំមុនការចូលចតកំពង់ផែ.................................................6
មាត្រា ៩. ការអនុញ្ញាត ឬការបដិសេធចូលចតនៅកំពង់ផែ.................................................6
មាត្រា ១០. ករណីប្រធានសក្តិ ឬគ្រោះថ្នាក់.................................................7
ផ្នែកទី ៣. ការប្រើកំពង់ផែ.................................................7
មាត្រា ១១. ការប្រើកំពង់ផែ.................................................7
ផ្នែកទី ៤. អធិការកិច្ច និងសកម្មភាពតាមដាន.................................................8
មាត្រា ១២. កម្រិត និងអាទិភាពសម្រាប់អធិការកិច្ច.................................................8
មាត្រា ១៣. ដំណើរការនៃការធ្វើអធិការកិច្ច.................................................8
មាត្រា ១៤. លទ្ធផលនៃការធ្វើអធិការកិច្ច.................................................9
មាត្រា ១៥. ការបញ្ជូនលទ្ធផលនៃការធ្វើអធិការកិច្ច.................................................9
មាត្រា ១៦. ការផ្លាស់ប្តូរព័ត៌មានតាមអេឡិចត្រូនិច.................................................9
មាត្រា ១៧. ការបណ្តុះបណ្តាលមន្ត្រីអធិការកិច្ច.................................................10
មាត្រា ១៨. វិធានការរដ្ឋម្ចាស់កំពង់ផែក្រោយការធ្វើអធិការកិច្ច.................................................10
មាត្រា ១៩. ព័ត៌មានឧបាស្រ័យនៅក្នុងរដ្ឋម្ចាស់កំពង់ផែ.................................................11
ផ្នែកទី ៥. តួនាទីរដ្ឋម្ចាស់ទង់ជាតិ.................................................11
មាត្រា ២០. តួនាទីរដ្ឋម្ចាស់ទង់ជាតិ.................................................11
ផ្នែកទី ៦. តម្រូវការរដ្ឋកំពុងអភិវឌ្ឍ.................................................12
មាត្រា ២១. តម្រូវការរដ្ឋកំពុងអភិវឌ្ឍ.................................................12
ផ្នែកទី ៧. ការដោះស្រាយវិវាទ.................................................13
មាត្រា ២២. ការដោះស្រាយវិវាទដោយសន្តិវិធី.................................................13
ផ្នែកទី ៨. ភាគីមិនមែនជាសមាជិក.................................................14
មាត្រា ២៣. ភាគីមិនមែនជាសមាជិកនៃកិច្ចព្រមព្រៀងនេះ.................................................14
ផ្នែកទី ៩. ការត្រួតពិនិត្យ ការពិនិត្យឡើងវិញ និងការវាយតម្លៃ.................................................14
មាត្រា ២៤. ការត្រួតពិនិត្យ ការពិនិត្យឡើងវិញ និងការវាយតម្លៃ.................................................14
ផ្នែកទី ១០. អវសានប្បញ្ញត្តិ.................................................14

មាត្រា ២៥. ការចុះហត្ថលេខា ..... 14
មាត្រា ២៦. ការផ្តល់សច្ចាប័ន ការទទួលយក ឬការយល់ព្រម ..... 14
មាត្រា ២៧. ការចូលជាសមាជិក ..... 14
មាត្រា ២៨. ការចូលរួមរបស់អង្គការសមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់ ..... 15
មាត្រា ២៩. ការចូលជាធរមាន ..... 15
មាត្រា ៣០. ការបម្រុងទុក និងការលើកលែង ..... 16
មាត្រា ៣១. សេចក្តីប្រកាស និងសេចក្តីថ្លែងការណ៍ ..... 16
មាត្រា ៣២. ការអនុវត្តបណ្តោះអាសន្ន ..... 16
មាត្រា ៣៣. វិសោធនកម្ម ..... 16
មាត្រា ៣៤. ឧបសម្ព័ន្ធ ..... 17
មាត្រា ៣៥. ការដកខ្លួនចេញ ..... 17
មាត្រា ៣៦. អ្នកតម្កល់ឯកសារ ..... 17
មាត្រា ៣៧. អត្ថបទស្របច្បាប់ ..... 17
ឧបសម្ព័ន្ធ ក. ព័ត៌មានដែលត្រូវផ្តល់ជាមុនដោយនាវាដែលស្នើសុំការចូលចតនៅកំពង់ផែ ..... 19
ឧបសម្ព័ន្ធ ខ. នីតិវិធីអធិការកិច្ចរដ្ឋម្ចាស់កំពង់ផែ ..... 20
ឧបសម្ព័ន្ធ គ. របាយការណ៍លទ្ធផលនៃការធ្វើអធិការកិច្ច ..... 22
ឧបសម្ព័ន្ធ ឃ. ប្រព័ន្ធព័ត៌មានស្តីពីវិធានការរដ្ឋម្ចាស់កំពង់ផែ ..... 24
ឧបសម្ព័ន្ធ ង. គោលការណ៍ណែនាំសម្រាប់ការបណ្តុះបណ្តាលអធិការ ..... 25
ឧបសម្ព័ន្ធ ច. ព្រះរាជក្រមប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិក នៃកិច្ចព្រមព្រៀងស្តីពីវិធានការរដ្ឋម្ចាស់កំពង់ផែ ដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានការអនុញ្ញាត និងគ្មានរបាយការណ៍ ..... 26

# បុព្វកថា

**ភាគីទាំងអស់នៃកិច្ចព្រមព្រៀងនេះ៖**

**ដោយព្រួយបារម្ភយ៉ាងខ្លាំង** អំពីការបន្តកើតឡើងនូវការនេសាទខុសច្បាប់ គ្មានការអនុញ្ញាត និងគ្មានរបាយការណ៍ និងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដែលបង្កគ្រោះថ្នាក់ដល់ផលស្តុក ប្រព័ន្ធអេកូឡូស៊ីសមុទ្រ និងជីវភាពរស់នៅរបស់អ្នកនេសាទស្របច្បាប់ និងការកើនឡើងនូវតម្រូវការសន្តិសុខស្បៀងនៅលើពិភពលោក

**ដោយយល់ច្បាស់** អំពីតួនាទីរបស់រដ្ឋម្ចាស់កំពង់ផែក្នុងការអនុម័តវិធានការដ៏មានប្រសិទ្ធភាព ដើម្បីជំរុញការប្រើប្រាស់ដោយនិរន្តរភាព និងការអភិរក្សរយៈពេលយូរនៃធនធានជលផលសមុទ្រ

**ដោយទទួលស្គាល់ថា** វិធានការប្រយុទ្ធប្រឆាំងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត គឺជាការទទួលខុសត្រូវរបស់រដ្ឋម្ចាស់ទង់ជាតិ និងអនុវត្តយុត្តាធិការដែលមានទាំងអស់ឱ្យស្របទៅតាមច្បាប់អន្តរជាតិ រួមមានវិធានការរដ្ឋម្ចាស់កំពង់ផែ វិធានការរដ្ឋម្ចាស់ឆ្នេរ វិធានការទីផ្សារ និងវិធានការពាក់ព័ន្ធផ្សេងទៀត ដើម្បីធានាថាប្រជាជាតិទាំងនោះមិនគាំទ្រ ឬមិនពាក់ព័ន្ធការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត

**ដោយទទួលស្គាល់ថា** វិធានការរដ្ឋម្ចាស់កំពង់ផែផ្តល់មធ្យោបាយដ៏មានឥទ្ធិពលនិងមានប្រសិទ្ធភាពក្នុងការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានការអនុញ្ញាត និងគ្មានរបាយការណ៍

**ដោយយល់ដឹង**ពីភាពចាំបាច់សម្រាប់បង្កើនកិច្ចសម្របសម្រួលទាំងនៅថ្នាក់តំបន់និងថ្នាក់អន្តរជាតិក្នុងការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានការអនុញ្ញាត និងគ្មានរបាយការណ៍តាមរយៈការអនុវត្តវិធានការរដ្ឋម្ចាស់កំពង់ផែ

**ដោយទទួលស្គាល់** ចំពោះការកើនឡើងយ៉ាងឆាប់រហ័សនូវបច្ចេកវិទ្យាទំនាក់ទំនង ទិន្នន័យមូលដ្ឋានបណ្តាញការងារ និងកំណត់ត្រាជាសកល ដែលគាំទ្រដល់វិធានការរដ្ឋម្ចាស់កំពង់ផែ

**ដោយទទួលស្គាល់** ពីភាពចាំបាច់សម្រាប់ជួយដល់ប្រទេសកំពុងអភិវឌ្ឍក្នុងការអនុម័ត និងការអនុវត្តវិធានការរដ្ឋម្ចាស់កំពង់ផែ

**ដោយកត់សម្គាល់** ពីការអំពាវនាវរបស់សហគមន៍អន្តរជាតិ តាមរយៈប្រព័ន្ធអង្គការសហប្រជាជាតិ រួមទាំងមហាសន្និបាតរបស់អង្គការសហប្រជាជាតិ និងគណៈកម្មការជលផលនៃអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិហៅកាត់ថា “FAO” ដែលបង្កើតក្របខ័ណ្ឌច្បាប់ក្នុងកម្រិតស្តង់ដារអប្បបរមាជាផ្លូវការសម្រាប់វិធានការរដ្ឋម្ចាស់កំពង់ផែ ដោយផ្អែកលើផែនការសកម្មភាពអន្តរជាតិរបស់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិឆ្នាំ២០០១ស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានការអនុញ្ញាត និងគ្មានរបាយការណ៍ និងគម្រោងការគំរូនៃវិធានការរដ្ឋម្ចាស់កំពង់ផែសម្រាប់ប្រយុទ្ធប្រឆាំងការនេសាទខុសច្បាប់ គ្មានការអនុញ្ញាត និងគ្មានរបាយការណ៍របស់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិឆ្នាំ២០០៥

**ដោយចងចាំថា** នៅក្នុងការអនុវត្តអធិបតេយ្យភាពលើកំពង់ផែដែលស្ថិតនៅក្នុងដែនសមុទ្ររបស់ខ្លួន រដ្ឋទាំងឡាយអាចអនុម័តនូវវិធានការដ៏មុឺងម៉ាត់បន្ថែមទៀត ដោយយោងតាមច្បាប់អន្តរជាតិ

**ដោយរំលឹកឡើងវិញ** នូវបទប្បញ្ញត្តិទាំងឡាយនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រដែលបានអនុម័តនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨២ ដែលហៅកាត់ថា “អនុសញ្ញា”

## ផ្នែកទី ១. បទប្បញ្ញត្តិទូទៅ

### មាត្រា ១. ការប្រើពាក្យស័ព្ទ

សម្រាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ៖

(ក) **"វិធានការគ្រប់គ្រង និងអភិរក្ស"** សំដៅដល់វិធានការទាំងឡាយសម្រាប់គ្រប់គ្រង និងអភិរក្សធនធានសមុទ្រមានជីវិតដែលបានអនុម័តនិងអនុវត្តស្របតាមបទប្បញ្ញត្តិពាក់ព័ន្ធនឹងច្បាប់អន្តរជាតិទាំងឡាយ រួមទាំងបទប្បញ្ញត្តិដែលមានចែងនៅក្នុងអនុសញ្ញា

(ខ) **"ត្រី"** សំដៅដល់ធនធានជលផលសមុទ្រមានជីវិតគ្រប់ប្រភេទទាំងអស់ ទោះជាផលិតផលកែច្នៃឬមិនទាន់កែច្នៃក៏ដោយ

(គ) **"ការនេសាទ"** សំដៅដល់ការរុករក ការទាក់ទាញ ការស្វែងរក ការចាប់ ការទាញយក ឬការប្រមូលផលត្រី ឬសកម្មភាពណាមួយដែលគិតថាជាលទ្ធផលពីការទាក់ទាញ ការស្វែងរក ការចាប់ ការទាញយក ឬការប្រមូលផលត្រី

(ឃ) **"សកម្មភាពទាក់ទងនឹងការនេសាទ"** សំដៅដល់ប្រតិបត្តិការណាមួយក្នុងការគាំទ្រ ឬការរៀបចំសម្រាប់ការនេសាទ រួមមានការឡើងផលនេសាទ ការវេចខ្ចប់ ការកែច្នៃ ការផ្ទេរ ឬ ការដឹកជញ្ជូនផលត្រីដែលពីមុនមកមិនធ្លាប់បានចូលចតនៅកំពង់ផែមួយ ក៏ដូចជាការផ្តល់បុគ្គលិក ប្រេងឥន្ធនៈ ឧបករណ៍ និងការផ្គត់ផ្គង់ផ្សេងៗទៀតនៅក្នុងសមុទ្រ

(ង) **"ការនេសាទខុសច្បាប់ គ្មានការអនុញ្ញាត និងគ្មានរបាយការណ៍"** សំដៅលើសកម្មភាពដែលមានចែងក្នុងកថាខណ្ឌទី៣ នៃផែនការសកម្មភាពអន្តរជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានការអនុញ្ញាត និងគ្មានរបាយការណ៍ដែលហៅកាត់ថា "IUU Fishing" របស់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិឆ្នាំ២០០១

(ច) **"ភាគី"** សំដៅដល់រដ្ឋមួយ ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់មួយដែលបានយល់ព្រមតាមកិច្ចព្រមព្រៀងនេះនៅពេលកិច្ចព្រមព្រៀងនេះចូលជាធរមាន

(ឆ) **"កំពង់ផែ"** រួមបញ្ចូលទាំងចំណតក្នុងសមុទ្រក្រៅ និងឋបនាដ្ឋាន (សំណង់) ផ្សេងៗ សម្រាប់ការឡើងផលនេសាទ ការផ្ទេរ ការវេចខ្ចប់ ការកែច្នៃ ការចាក់ប្រេងឥន្ធនៈ ឬការផ្គត់ផ្គង់ផ្សេងៗទៀត

(ជ) **"អង្គការសមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់"** សំដៅលើអង្គការសមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់មួយដែលរដ្ឋជាសមាជិករបស់អង្គការនោះ បានផ្ទេរសមត្ថកិច្ចលើកិច្ចការដែលគ្របដណ្តប់ដោយកិច្ចព្រមព្រៀងនេះ រួមទាំងសិទ្ធិក្នុងការធ្វើសេចក្តីសម្រេចជាផ្លូវការទាំងឡាយជំនួសឱ្យរដ្ឋជាសមាជិករបស់អង្គការនេះ សម្រាប់បញ្ហាទាំងអស់នោះ

(ឈ) **"អង្គការគ្រប់គ្រងជលផលថ្នាក់តំបន់"** សំដៅដល់អង្គការជលផលអន្តររដ្ឋាភិបាលមួយ ឬការរៀបចំសមស្របមួយ ដែលមានសមត្ថកិច្ច ក្នុងការបង្កើតវិធានការគ្រប់គ្រង និងអភិរក្ស ធនធានជលផល

(ញ) **"នាវា"** សំដៅដល់នាវាណាមួយឬកប៉ាល់ផ្សេងៗឬទូកប្រើសម្រាប់ឬបំពាក់សម្ភារៈបរិក្ខារប្រើសម្រាប់ ឬក្នុងគោលបំណងប្រើប្រាស់សម្រាប់ ការនេសាទ ឬសកម្មភាពពាក់ព័ន្ធនឹងការនេសាទ។

### មាត្រា ២. គោលបំណង

គោលបំណងនៃកិច្ចព្រមព្រៀងនេះ គឺដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានការអនុញ្ញាត និងគ្មានរបាយការណ៍ តាមរយៈការអនុវត្តវិធានការរដ្ឋម្ចាស់កំពង់ផែឱ្យមានប្រសិទ្ធភាពនិងដើម្បីធានាបាននូវការអភិរក្សយូរអង្វែង ការប្រើធនធានជលផលសមុទ្រ និងប្រព័ន្ធអេកូឡូស៊ីសមុទ្រឱ្យមាននិរន្តរភាព។

៣. គ្មានករណីណាមួយដែលតម្រូវឱ្យភាគីមួយស្ថិតក្រោមកិច្ចព្រមព្រៀងនេះ មានឥទ្ធិពលទៅលើវិធានការឬសេចក្ដីសម្រេចទាំងអស់របស់អង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ណាមួយ ប្រសិនបើវិធានការ ឬសេចក្ដីសម្រេចទាំងនោះ មិនទាន់បានអនុម័តតាមច្បាប់អន្តរជាតិ។

៤. កិច្ចព្រមព្រៀងនេះត្រូវបានបកស្រាយនិងអនុវត្តស្របតាមច្បាប់អន្តរជាតិ រួមមានបទដ្ឋាននិងនិយាមអន្តរជាតិព្រមទាំងវិធានការទាំងឡាយ បង្កើតដោយអង្គការសមុទ្រអន្តរជាតិ និងលិខិតុបករណ៍អន្តរជាតិផ្សេងទៀត។

៥. ភាគីទាំងអស់ត្រូវបំពេញកាតព្វកិច្ច និងអនុលោមឱ្យបានពេញលេញតាមកិច្ចព្រមព្រៀងនេះនិងត្រូវអនុវត្តសិទ្ធិដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ ដោយមិនបង្កឱ្យមានការរំលោភបំពានសិទ្ធិ។

## មាត្រា ៥. សមាហរណកម្ម និងការសម្របសម្រួលថ្នាក់ជាតិ

ភាគីនីមួយៗ ត្រូវអនុវត្តកិច្ចការទៅតាមលទ្ធភាពដែលអាចធ្វើបានដូចខាងក្រោម៖

(ក) ធ្វើសមាហរណកម្ម ឬសម្របសម្រួលវិធានការរដ្ឋម្ចាស់កំពង់ផែដែលទាក់ទងនឹងជលផល ជាមួយប្រព័ន្ធគ្រប់គ្រងទូលំទូលាយរបស់រដ្ឋម្ចាស់កំពង់ផែ

(ខ) ធ្វើសមាហរណកម្មវិធានការរដ្ឋម្ចាស់កំពង់ផែ ជាមួយវិធានការផ្សេងទៀត ដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានការអនុញ្ញាត និងគ្មានរបាយការណ៍និងសកម្មភាពពាក់ព័ន្ធផ្សេងទៀតដែលគាំទ្រដល់ការនេសាទខុសច្បាប់ ដោយរួមបញ្ចូលនូវផែនការសកម្មភាពអន្តរជាតិស្ដីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានការអនុញ្ញាត និងគ្មានរបាយការណ៍របស់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិឆ្នាំ២០០១

(គ) ចាត់វិធានការផ្លាស់ប្ដូរព័ត៌មានជាមួយស្ថាប័នជាតិពាក់ព័ន្ធនានា និងសម្របសម្រួលសកម្មភាពជាមួយស្ថាប័នទាំងនោះក្នុងការអនុវត្តកិច្ចព្រមព្រៀងនេះ។

## មាត្រា ៦. កិច្ចសហប្រតិបត្តិការ និងការផ្លាស់ប្ដូរព័ត៌មាន

១. ដើម្បីជំរុញការអនុវត្តកិច្ចព្រមព្រៀងនេះឱ្យមានប្រសិទ្ធភាព និងតម្រូវការរក្សាការសម្ងាត់ឱ្យបានត្រឹមត្រូវភាគីទាំងអស់ត្រូវសហការ និងផ្លាស់ប្ដូរព័ត៌មានជាមួយរដ្ឋពាក់ព័ន្ធ អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ អង្គការអន្តរជាតិ និងអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ ដោយរាប់បញ្ចូលនូវវិធានការ ដែលបានអនុម័តដោយអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ទាំងនោះ ទាក់ទងនឹងគោលបំណងនៃកិច្ចព្រមព្រៀងនេះ។

២. ភាគីនីមួយៗត្រូវអនុវត្តវិធានការទាំងនេះឱ្យបានខ្លាំងក្លាតាមលទ្ធភាពដែលអាចធ្វើបាន ដើម្បីគាំទ្រដល់វិធានការគ្រប់គ្រង និងអភិរក្សដែលបានអនុម័តដោយរដ្ឋ និងអង្គការអន្តរជាតិពាក់ព័ន្ធនានា។

៣. ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះឱ្យមានប្រសិទ្ធភាពស្របទៅតាមស្ថានភាពសមស្របភាគីទាំងអស់ ត្រូវសហការគ្នាទាំងថ្នាក់អនុតំបន់ ថ្នាក់តំបន់ និងថ្នាក់ពិភពលោក តាមរយៈអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ ឬអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ និងអង្គការផ្សេងៗទៀត។

# ផ្នែកទី ២. ការចូលចតនៅកំពង់ផែ

## មាត្រា ៧. ការកំណត់កំពង់ផែ

១. ភាគីនីមួយៗ ត្រូវកំណត់ និងផ្សព្វផ្សាយអំពីកំពង់ផែទាំងអស់ សម្រាប់ឱ្យនាវាអាចស្នើសុំចូលចត ស្របតាមកិច្ចព្រមព្រៀងនេះ។ ភាគីនីមួយៗ ត្រូវផ្ដល់បញ្ជីឈ្មោះកំពង់ផែដែលបានកំណត់ទៅអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ ដើម្បីផ្សព្វផ្សាយជាសាធារណៈ។

២. ភាគីនីមួយៗ ត្រូវធានាឱ្យអស់លទ្ធភាពថាគ្រប់កំពង់ផែដែលបានកំណត់ និងផ្សព្វផ្សាយដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ មានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើអធិការកិច្ចតាមកិច្ចព្រមព្រៀងនេះ។

## មាត្រា ៨. សំណើសុំមុនការចូលចតកំពង់ផែ

១. ភាគីនីមួយៗ ត្រូវតម្រូវឱ្យមានព័ត៌មានក្នុងកម្រិតស្តង់ដារអប្បបរមាមួយ ដូចមានចែងនៅក្នុងឧបសម្ព័ន្ធ "ក" ដែលត្រូវតែផ្តល់ឱ្យបានមុនពេលអនុញ្ញាតឱ្យនាវាចូលចតក្នុងកំពង់ផែរបស់ខ្លួន។

២. ភាគីនីមួយៗ ត្រូវតម្រូវឱ្យមានព័ត៌មានតាមកថាខណ្ឌទី១ នៃមាត្រានេះ ដោយត្រូវផ្តល់ព័ត៌មានឱ្យបានគ្រប់គ្រាន់ ដើម្បីឱ្យរដ្ឋម្ចាស់កំពង់ផែ មានពេលគ្រប់គ្រាន់ក្នុងការត្រួតពិនិត្យព័ត៌មានទាំងនោះ។

## មាត្រា ៩. ការអនុញ្ញាត ឬការបដិសេធចូលចតនៅកំពង់ផែ

១. បន្ទាប់ពីបានទទួលព័ត៌មានពាក់ព័ន្ធតាមតម្រូវការដូចមានចែងក្នុងមាត្រា៨ ក៏ដូចជាព័ត៌មានផ្សេងៗទៀតដែលអាចជាតម្រូវការសម្រាប់កំណត់ថា តើនាវាដែលកំពុងស្នើសុំចូលចតនៅក្នុងកំពង់ផែនោះ មានពាក់ព័ន្ធនឹងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ឬធ្វើសកម្មភាពពាក់ព័ន្ធផ្សេង ទៀតដែលគាំទ្រដល់ការនេសាទខុសច្បាប់ដែរឬទេ ភាគីម្ចាស់កំពង់ផែនោះត្រូវសម្រេចចិត្តថាតើគួរអនុញ្ញាត ឬបដិសេធការចូលចតនៃនាវានោះ ហើយត្រូវជូនដំណឹងពីសេចក្តីសម្រេចនេះទៅកាន់នាវា ឬតំណាងរបស់នាវានោះ។

២. ក្នុងករណីអនុញ្ញាតឱ្យនាវាចូលចត មេបញ្ជាការនាវា ឬតំណាងនាវា ត្រូវបង្ហាញលិខិតអនុញ្ញាតសម្រាប់ការចូលចតដល់អាជ្ញាធរមានសមត្ថកិច្ចទាំងអស់នៃភាគីម្ចាស់កំពង់ផែអំឡុងពេលនាវាមកដល់កំពង់ផែ។

៣. ក្នុងករណីបដិសេធការចូលចត ភាគីនីមួយៗ ត្រូវជូនដំណឹងពីសេចក្តីសម្រេចរបស់ខ្លួន ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះទៅកាន់រដ្ឋម្ចាស់ទង់ជាតិនៃនាវា រដ្ឋមានដែនសមុទ្រពាក់ព័ន្ធ អង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ និងអង្គការអន្តរជាតិផ្សេងៗទៀត តាមលទ្ធភាពដែលអាចធ្វើបាន។

៤. ដោយគ្មានព្យសនកម្មពីកថាខណ្ឌទី១នៃមាត្រានេះ នៅពេលភាគីមួយមានភស្តុតាងគ្រប់គ្រាន់បង្ហាញថានាវាដែលកំពុងសុំចូលចតនៅកំពង់ផែនោះ ធ្លាប់ពាក់ព័ន្ធនឹងការនេសាទខុសច្បាប់ គ្មានការអនុញ្ញាត និងគ្មានរបាយការណ៍ ឬធ្វើសកម្មភាពពាក់ព័ន្ធផ្សេងទៀតដែលគាំទ្រដល់ការនេសាទខុសច្បាប់ ជាពិសេសនៅពេលឃើញឈ្មោះនាវានោះស្ថិតក្នុងបញ្ជីនាវាពាក់ព័ន្ធនឹងការនេសាទខុសច្បាប់ គ្មានការអនុញ្ញាត និងគ្មានរបាយការណ៍ ឬធ្វើសកម្មភាពពាក់ព័ន្ធផ្សេងទៀត ដែលគាំទ្រដល់ការនេសាទខុសច្បាប់ ដែលបានកំណត់ដោយអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ពាក់ព័ន្ធ ស្របតាមវិធាន និងនីតិវិធីនៃអង្គការនោះ និងដោយអនុលោមតាមច្បាប់អន្តរជាតិ ភាគីម្ចាស់កំពង់ផែត្រូវបដិសេធការចូលចតនៃនាវានោះ នៅកំពង់ផែរបស់ខ្លួនស្របតាមកថាខណ្ឌទី២ និងទី៣នៃមាត្រា៤។

៥. ទោះបីជាមានចែងក្នុងកថាខណ្ឌទី៣ និងទី៤ នៃមាត្រានេះក៏ដោយ ភាគីម្ចាស់កំពង់ផែក៏អាចអនុញ្ញាតឱ្យនាវាមួយចូលចតកំពង់ផែរបស់ខ្លួនបាន ដោយយោងលើកថាខណ្ឌដោយឡែក ក្នុងគោលបំណងធ្វើអធិការកិច្ចនាវា និងអនុវត្តសកម្មភាពសមស្របផ្សេងទៀតដោយអនុលោមទៅតាមច្បាប់អន្តរជាតិ ដែលមានប្រសិទ្ធភាពស្មើនឹងការបដិសេធការចូលចតក្នុងកំពង់ផែ ដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានការអនុញ្ញាត និងគ្មានរបាយការណ៍ និងសកម្មភាពពាក់ព័ន្ធផ្សេងទៀតដែលគាំទ្រដល់ការនេសាទខុសច្បាប់។

៦. យោងតាមកថាខណ្ឌទី៤ ឬទី៥ នៃមាត្រានេះ ភាគីម្ចាស់កំពង់ផែ ត្រូវបដិសេធការប្រើកំពង់ផែ របស់នាវាមួយក្នុងការឡើងផលនេសាទ ការផ្ទេរ ការវេចខ្ចប់ ការកែច្នៃត្រី និងការប្រើសេវាកម្មកំពង់ផែផ្សេងទៀតមានជាអាទិ៍ ការចាក់ប្រេងឥន្ធនៈ ការផ្គត់ផ្គង់សម្ភារៈបរិក្ខា ការថែទាំ និងការឡើងអូជួសជុល។ ក្នុងកថាខណ្ឌទី២ និងទី៣នៃ

មាត្រា១១ អាចអនុវត្តចំពោះករណីទាំងអស់ខាងលើ។ ការបដិសេធនៃការប្រើកំពង់ផែទាំងនេះ ត្រូវអនុវត្តដោយអនុលោមទៅតាមច្បាប់អន្តរជាតិ។

## មាត្រា ១០. ករណីប្រធានសក្តិ ឬគ្រោះថ្នាក់

អនុលោមតាមច្បាប់អន្តរជាតិ កិច្ចព្រមព្រៀងនេះ ពុំមានអ្វីប៉ះពាល់ដល់ការចូលចតនៃនាវានៅកំពង់ផែក្នុងករណីប្រធានសក្តិ ឬគ្រោះអាសន្នណាមួយ ឬក៏រាំងរដ្ឋម្ចាស់កំពង់ផែ ក្នុងការអនុញ្ញាតឱ្យនាវាមួយដែលកំពុងស្ថិតក្នុងភាពគ្រោះថ្នាក់ ឬគ្រោះអាសន្នចូលចតក្នុងកំពង់ផែ ដើម្បីជួយសង្គ្រោះមនុស្ស ឬនាវា ឬយន្តហោះ។

# ផ្នែកទី ៣. ការប្រើកំពង់ផែ

## មាត្រា ១១. ការប្រើកំពង់ផែ

១. នៅពេលនាវាមួយបានចូលកំពង់ផែណាមួយ ដើម្បីប្រើកំពង់ផែសម្រាប់ការឡើងផលនេសាទ ការផ្ទេរ ការវេចខ្ចប់ និងការកែច្នៃត្រី ដែលពីមុនពុំធ្លាប់បានចូលចត និងសម្រាប់សេវាកម្មកំពង់ផែផ្សេងៗទៀតមានជាអាទិ៍ ការចាក់ប្រេងឥន្ធនៈ ការផ្គត់ផ្គង់សម្ភារៈបរិក្ខា ការថែទាំ និងការឡើងអ៊ូជូសផុល ភាគីរដ្ឋម្ចាស់កំពង់ផែត្រូវតែបដិសេធការចូលចតនេះ ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានរបស់ខ្លួន និងឱ្យស្របតាមច្បាប់អន្តរជាតិរួមទាំងកិច្ចព្រមព្រៀងនេះ ក្នុងករណីដែល៖

(ក) ភាគីម្ចាស់កំពង់ផែរកឃើញថា នាវានោះមានលិខិតអនុញ្ញាតមិនមានសុពលភាពត្រឹមត្រូវ និងមិនអនុវត្តតាមការអនុញ្ញាតឱ្យធ្វើនេសាទ ឬសកម្មភាពពាក់ព័ន្ធនឹងការនេសាទដទៃ ទៀតដែលតម្រូវដោយរដ្ឋម្ចាស់ទង់ជាតិ

(ខ) ភាគីម្ចាស់កំពង់ផែរកឃើញថា នាវានោះមានលិខិតអនុញ្ញាតមិនមានសុពលភាពត្រឹមត្រូវ និងមិនអនុវត្តតាមការអនុញ្ញាតឱ្យធ្វើនេសាទ ឬសកម្មភាពពាក់ព័ន្ធនឹងការនេសាទដទៃទៀត នៅតំបន់ក្រោមយុត្តាធិការជាតិដែលតម្រូវដោយរដ្ឋម្ចាស់ឆ្នេរ

(គ) ភាគីម្ចាស់កំពង់ផែទទួលបានភស្តុតាងច្បាស់លាស់ថា ផលនេសាទនៅលើនាវាដែលបានពីការនេសាទល្មើសច្បាប់នៅក្នុងតំបន់ដែលស្ថិតក្រោមយុត្តាធិការជាតិនៃរដ្ឋម្ចាស់ឆ្នេរ

(ឃ) រដ្ឋម្ចាស់ទង់ជាតិមិនបានឆ្លើយតបទាន់ពេលវេលាលើសំណើរបស់រដ្ឋម្ចាស់កំពង់ផែ អំពីផលនេសាទនៅលើនាវាថា ត្រីដែលនេសាទបានមានលក្ខណៈត្រឹមត្រូវស្របតាមតម្រូវការបទដ្ឋានគតិយុត្តិរបស់អង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ពាក់ព័ន្ធ ដូចមានចែងក្នុងកថាខណ្ឌទី២ និង ទី៣នៃមាត្រា ៤

(ង) ភាគីម្ចាស់កំពង់ផែមានមូលហេតុត្រឹមត្រូវដែលអាចជឿជាក់បានថា នាវានោះអាចពាក់ព័ន្ធនឹងការនេសាទខុសច្បាប់ គ្មានការអនុញ្ញាត និងគ្មានរបាយការណ៍ឬធ្វើសកម្មភាពពាក់ព័ន្ធ ផ្សេងទៀតដែលគាំទ្រដល់ការនេសាទខុសច្បាប់ រួមទាំងប្រភេទនាវាដែលមានចែងក្នុងកថា ខណ្ឌទី៤ នៃមាត្រា៩ លុះត្រាតែនាវានោះ អាចបញ្ជាក់ថា៖

(i) ជានាវាដែលបានធ្វើសកម្មភាពស្របតាមវិធានការគ្រប់គ្រងនិងអភិរក្សដែលពាក់ព័ន្ធ ឬ

(ii) ក្នុងករណីមានការផ្លាស់ប្តូរបុគ្គលិក ផ្គត់ផ្គង់ប្រេងឥន្ធនៈ ឧបករណ៍នេសាទ និងការ ផ្គត់ផ្គង់ដទៃទៀតនៅលើសមុទ្រ។ ចំពោះនាវាដែលមិនទទួលបាននូវការផ្គត់ផ្គង់ក្នុងខណៈពេលនោះគឺជាប្រភេទនាវាដូចមានចែងក្នុងកថាខណ្ឌទី៤ នៃមាត្រា៩។

២. ទោះបីជាមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះក៏ដោយ ភាគីម្ចាស់កំពង់ផែអាចអនុញ្ញាតការចូលចតនៃនាវា ដែលត្រូវការប្រើសេវាកម្មកំពង់ផែ ក្នុងករណីដូចខាងក្រោម៖

(ក) មានការចាំបាច់ទាក់ទងទៅនឹងសុវត្ថិភាព ឬសុខភាពរបស់នាវិក ឬសុវត្ថិភាពរបស់នាវានៅពេលមានការផ្តល់ភស្តុតាងច្បាស់លាស់ដែលបញ្ជាក់ពីភាពចាំបាច់ទាំងនេះ ឬ

(ខ) នៅពេលនាវាដែលរងនូវការប៉ះទង្គិចបែកបាក់ ដែលត្រូវការចូលចតជាបន្ទាន់។

៣. បើភាគីម្ចាស់កំពង់ផែបានបដិសេធនូវការប្រើកំពង់ផែរបស់ខ្លួនស្របតាមកថាខណ្ឌទី១នៃមាត្រានេះ ភាគីម្ចាស់កំពង់ផែត្រូវជូនដំណឹងជាបន្ទាន់អំពីសេចក្តីសម្រេចរបស់ខ្លួនទៅដល់រដ្ឋម្ចាស់ទង់ជាតិ បណ្តារដ្ឋម្ចាស់ឆ្នេរ បណ្តាអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ និងបណ្តាអង្គការអន្តរជាតិពាក់ព័ន្ធផ្សេងៗទៀត។

៤. ភាគីម្ចាស់កំពង់ផែ ត្រូវលុបចោលនូវការបដិសេធលើការប្រើកំពង់ផែ ស្របតាមកថាខណ្ឌទី១នៃមាត្រានេះ ចំពោះនាវាដែលមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា អ្វីដែលបានបដិសេធនេះមានលក្ខណៈមិនគ្រប់គ្រាន់ ឬមានការភាន់ច្រឡំ ឬមូលហេតុទាំងអស់នោះ លែងមានសុពលភាព។

៥. បើភាគីម្ចាស់កំពង់ផែបានលុបចោលនូវការបដិសេធរបស់ខ្លួន ស្របតាមកថាខណ្ឌទី៤នៃមាត្រានេះ ត្រូវជូនដំណឹង ជាបន្ទាន់អំពីសេចក្តីប្រកាសនោះទៅដល់បណ្តាប្រទេស និងអង្គការពាក់ព័ន្ធ ស្របតាមកថាខណ្ឌទី៣នៃមាត្រានេះ។

## ផ្នែកទី ៤. អធិការកិច្ច និងសកម្មភាពតាមដាន

### មាត្រា ១២. កម្រិត និងអាទិភាពសម្រាប់អធិការកិច្ច

១. ភាគីនីមួយៗត្រូវធ្វើអធិការកិច្ចឱ្យបានទៀងទាត់នូវចំនួននាវានៅតាមកំពង់ផែរបស់ខ្លួនជារៀងរាល់ឆ្នាំដើម្បីសម្រេចតាមគោលបំណងនៃកិច្ចព្រមព្រៀងនេះ។

២. ភាគីទាំងអស់ត្រូវស្វែងរកការឯកភាពក្នុងកម្រិតអប្បបរមា សម្រាប់ការធ្វើអធិការកិច្ចនាវា ឱ្យបានត្រឹមត្រូវតាមរយៈអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ ឬអង្គការផ្សេងៗទៀត។

៣. ក្នុងការកំណត់នាវាដែលត្រូវធ្វើអធិការកិច្ច ភាគីម្ចាស់កំពង់ផែត្រូវផ្តល់អាទិភាពចំពោះ៖

(ក) នាវាដែលធ្លាប់ត្រូវបានបដិសេធមិនឱ្យចូលចតនៅកំពង់ផែ ឬមិនឱ្យប្រើកំពង់ផែ ដោយយោងតាមកិច្ចព្រមព្រៀងនេះ

(ខ) មានការស្នើសុំឱ្យធ្វើអធិការកិច្ចពីភាគីរដ្ឋ ឬអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ពាក់ព័ន្ធផ្សេងទៀត ដោយមានភស្តុតាងបញ្ជាក់ថា នាវានេះមានការពាក់ព័ន្ធនឹងការនេសាទខុសច្បាប់ គ្មានការអនុញ្ញាត និងគ្មានរបាយការណ៍ ឬធ្វើសកម្មភាពពាក់ព័ន្ធផ្សេងទៀតដែលគាំទ្រដល់ការនេសាទខុសច្បាប់

(គ) នាវាផ្សេងទៀតដែលមានការសង្ស័យខ្លាំងថា ជានាវាមានការពាក់ព័ន្ធនឹងការនេសាទខុសច្បាប់ គ្មានការអនុញ្ញាត និងគ្មានរបាយការណ៍ ឬធ្វើសកម្មភាពពាក់ព័ន្ធផ្សេងទៀតដែលគាំទ្រ ដល់ការនេសាទខុសច្បាប់។

### មាត្រា ១៣. ដំណើរការនៃការធ្វើអធិការកិច្ច

១. ភាគីនីមួយៗត្រូវធានាថា មន្ត្រីអធិការកិច្ចរបស់ខ្លួនអនុវត្តមុខងារ និងតួនាទីដូចមានចែងក្នុងឧបសម្ព័ន្ធ "ខ" ឱ្យបានក្នុងកម្រិតស្តង់ដារអប្បបរមា។

២. ភាគីនីមួយៗ ត្រូវធ្វើអធិការកិច្ចនៅកំពង់ផែរបស់ខ្លួនដូចខាងក្រោម៖

(ក) ធានាថា ការធ្វើអធិការកិច្ចបានប្រព្រឹត្តទៅដោយមន្ត្រីអធិការកិច្ចដែលមានសមត្ថភាព និងមានសិទ្ធិអំណាចគ្រប់គ្រាន់សម្រាប់ធ្វើកិច្ចការនេះ ដូចមានចែងក្នុងមាត្រា១៧

(ខ) ជានាថា នៅមុនពេលធ្វើអធិការកិច្ច មន្ត្រីអធិការកិច្ចត្រូវបង្ហាញឯកសារសម្គាល់ខ្លួនដែល បញ្ជាក់ថាជាមន្ត្រីអធិការកិច្ចដល់មេបញ្ជាការនាវា

(គ) ជានាថា មន្ត្រីអធិការកិច្ចត្រួតពិនិត្យគ្រប់ទីកន្លែងពាក់ព័ន្ធទាំងអស់នៅលើនាវា ផលនេសាទ លើនាវា ឧបករណ៍នេសាទ និងឧបករណ៍ផ្សេងៗទៀត សម្ភារៈបរិក្ខារ ឯកសារ ឬកំណត់ត្រានៅលើនាវាពាក់ព័ន្ធ ដើម្បីផ្ទៀងផ្ទាត់ស្របទៅតាមវិធានការគ្រប់គ្រង និងការអភិរក្សដែលពាក់ព័ន្ធ

(ឃ) តម្រូវឱ្យមេបញ្ជាការនាវាផ្តល់កិច្ចសហការ និងព័ត៌មានចាំបាច់ទាំងអស់ដល់មន្ត្រីអធិការកិច្ច ហើយបង្ហាញឯកសារពាក់ព័ន្ធ ឬឯកសារថតចម្លង តាមតម្រូវការរបស់មន្ត្រីអធិការកិច្ច

(ង) ក្នុងករណីមានការសម្របសម្រួលល្អជាមួយរដ្ឋម្ចាស់ទង់ជាតិរបស់នាវា ត្រូវអញ្ជើញរដ្ឋម្ចាស់ទង់ជាតិនោះឱ្យចូលរួមក្នុងការធ្វើអធិការកិច្ច

(ច) ត្រូវប្រឹងប្រែងឱ្យអស់លទ្ធភាព ដើម្បីជៀសវាងការពន្យារពេលក្នុងការធ្វើអធិការកិច្ចនាវា កាត់បន្ថយការរំខាន និងការខាតពេលវេលា រួមទាំងវត្តមានមន្ត្រីអធិការកិច្ចដែលមិនចាំបាច់នៅលើនាវា និងជៀសវាងនូវសកម្មភាពណាមួយដែលធ្វើឱ្យខូចគុណភាពផលនេសាទនៅលើនាវា

(ឆ) ត្រូវប្រឹងប្រែងឱ្យអស់លទ្ធភាព ដើម្បីសម្របសម្រួល ទំនាក់ទំនងជាមួយមេបញ្ជាការនាវា ឬប្រធាននាវិក ដើម្បីឱ្យមន្ត្រីអធិការកិច្ចមានអ្នកបកប្រែចូលរួមការងារនៅកន្លែងដែលអាច និងចាំបាច់ទាំងអស់លើនាវា ក្នុងការធ្វើអធិការកិច្ច

(ជ) ជានាថា ការធ្វើអធិការកិច្ចទាំងអស់ត្រូវបានប្រព្រឹត្តទៅដោយលក្ខណៈត្រឹមត្រូវ តម្លាភាព និងមិនរើសអើង ហើយមិនត្រូវមានការបំពានណាមួយចំពោះនាវានោះ និង

(ឈ) មិនត្រូវរំខានដល់លទ្ធភាពនៃការទំនាក់ទំនងរបស់មេបញ្ជាការនាវាជាមួយអាជ្ញាធរ នៃរដ្ឋម្ចាស់ទង់ជាតិដោយយោងតាមច្បាប់អន្តរជាតិ។

## មាត្រា ១៤. លទ្ធផលនៃការធ្វើអធិការកិច្ច

ភាគីនីមួយៗ ត្រូវធ្វើរបាយការណ៍ក្នុងកម្រិតស្តង់ដារអប្បបរមា ដោយរួមបញ្ចូលព័ត៌មានដូចមានចែងក្នុងឧបសម្ព័ន្ធ "គ" នៅក្នុងរបាយការណ៍ជាលាយលក្ខណ៍អក្សរអំពីលទ្ធផលនៃការធ្វើអធិការកិច្ចម្តងៗ។

## មាត្រា ១៥. ការបញ្ជូនលទ្ធផលនៃការធ្វើអធិការកិច្ច

ភាគីនីមួយៗ ត្រូវបញ្ជូនលទ្ធផលនៃការធ្វើអធិការកិច្ចនាវាទៅរដ្ឋម្ចាស់ទង់ជាតិរបស់នាវានីមួយៗ ឱ្យមានលក្ខណៈត្រឹមត្រូវ ដោយផ្ញើទៅកាន់៖

(ក) ភាគី និងរដ្ឋពាក់ព័ន្ធរួមមាន៖

(i) រដ្ឋដែលមានភស្តុតាងតាមរយៈការធ្វើអធិការកិច្ចបង្ហាញថា នាវាធ្លាប់ពាក់ព័ន្ធនឹងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ឬធ្វើសកម្មភាពពាក់ព័ន្ធ ផ្សេងទៀតដែលគាំទ្រដល់ការនេសាទខុសច្បាប់នៅក្នុងដែនសមុទ្រដែលស្ថិតក្រោមយុត្តាធិការជាតិនៃរដ្ឋនោះ

(ii) រដ្ឋដែលមានមេបញ្ជាការនាវា មានសញ្ជាតិជាពលរដ្ឋនៃប្រទេសនោះ

(ខ) អង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ពាក់ព័ន្ធនានា

(គ) អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ និងអង្គការអន្តរជាតិពាក់ព័ន្ធផ្សេងទៀត។

## មាត្រា ១៦. ការផ្លាស់ប្តូរព័ត៌មានតាមអេឡិចត្រូនិច

១. ដើម្បីសម្រួលដល់ការអនុវត្តកិច្ចព្រមព្រៀងនេះ ភាគីនីមួយៗ ត្រូវបង្កើតយន្តការទំនាក់ទំនងដែលអនុញ្ញាតដល់ការផ្លាស់ប្តូរព័ត៌មានជាសារអេឡិចត្រូនិចដោយផ្ទាល់ តាមដែលអាចធ្វើទៅបានដោយស្ថិតក្នុងលក្ខខណ្ឌសម្ងាត់ដ៏សមស្រប។

២. តាមលទ្ធភាពដែលអាចធ្វើបាន និងលក្ខខណ្ឌសម្ងាត់សមស្រប ភាគីទាំងអស់ត្រូវសហការគ្នាដើម្បីបង្កើតយន្តការចែករំលែកព័ត៌មានមួយ ដែលអាចជាអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិជាអ្នកសម្របសម្រួល ដោយភ្ជាប់ជាមួយនឹងការផ្តួចផ្តើមរបស់ពហុភាគី និងអន្តររដ្ឋាភិបាលពាក់ព័ន្ធផ្សេងៗ និងដើម្បីជួយសម្រួលដល់ការផ្លាស់ប្តូរព័ត៌មាននៅក្នុងប្រព័ន្ធទិន្នន័យពាក់ព័ន្ធនានាដែលមានស្រាប់តាមកិច្ចព្រមព្រៀងនេះ។

៣. ភាគីនីមួយៗត្រូវចាត់តាំងអាជ្ញាធរមានសមត្ថកិច្ចដែលត្រូវដើរតួជាអ្នកទំនាក់ទំនង សម្រាប់ការផ្លាស់ប្តូរព័ត៌មានស្ថិតនៅក្រោមកិច្ចព្រមព្រៀងនេះ។ ភាគីនីមួយៗ ត្រូវជូនដំណឹងដល់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិនូវសមត្ថកិច្ចដែលត្រូវបានតែងតាំងនោះ។

៤. ភាគីនីមួយៗ ត្រូវគ្រប់គ្រងព័ត៌មានដែលនឹងត្រូវបញ្ជូនតាមរយៈយន្តការណាមួយដែលបានបង្កើតឡើងស្របតាមកថាខណ្ឌទី១ នៃមាត្រានេះឱ្យមានសង្គតិភាពជាមួយឧបសម្ព័ន្ធ "ឃ"។

៥. អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ ត្រូវស្នើអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ពាក់ព័ន្ធឱ្យផ្តល់ព័ត៌មានទាក់ទងនឹងវិធានការឬសេចក្តីសម្រេចទាំងឡាយដែលបានអនុម័ត និងអនុវត្តពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងនេះ សម្រាប់ធ្វើសមាហរណកម្មរបស់ខ្លួនតាមដែលអាចធ្វើទៅបាន និងរក្សាការសម្ងាត់ សមស្របក្នុងយន្តការចែករំលែកព័ត៌មានដូចមានចែងក្នុងកថាខ័ណ្ឌទី២ នៃមាត្រានេះ។

## មាត្រា ១៧. ការបណ្តុះបណ្តាលមន្ត្រីអធិការកិច្ច

ភាគីនីមួយៗត្រូវធានាថាមន្ត្រីអធិការកិច្ចរបស់ខ្លួន ទទួលបានការបង្ហាត់បង្រៀនត្រឹមត្រូវ តាមគោលការណ៍ណែនាំស្តីពីការបណ្តុះបណ្តាលមន្ត្រីអធិការកិច្ចនៅក្នុងឧបសម្ព័ន្ធ "ង"។ ភាគីទាំងអស់ត្រូវស្វែងរកកិច្ចសហការក្នុងការងារនេះ។

## មាត្រា ១៨. វិធានការរដ្ឋម្ចាស់កំពង់ផែក្រោយការធ្វើអធិការកិច្ច

១. ក្រោយធ្វើអធិការកិច្ចរួច ភាគីដែលមានមូលហេតុច្បាស់លាស់អាចជឿជាក់បានថា នាវាណាមួយបានចូលរួមសកម្មភាពនេសាទខុសច្បាប់ គ្មានការអនុញ្ញាត និងគ្មានរបាយការណ៍ ឬធ្វើសកម្មភាពពាក់ព័ន្ធផ្សេងទៀត ដែលគាំទ្រដល់ការនេសាទខុសច្បាប់ ភាគីអធិការកិច្ចត្រូវ៖

(ក) ជូនដំណឹងជាបន្ទាន់ដល់រដ្ឋម្ចាស់ទង់ជាតិ និងរដ្ឋម្ចាស់ឆ្នេរពាក់ព័ន្ធនានា អង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ និងអង្គការអន្តរជាតិនានា ព្រមទាំងរដ្ឋដែលមានមេបញ្ជាការនាវាមាន សញ្ជាតិនៃរដ្ឋនោះ អំពីលទ្ធផលនៃការធ្វើអធិការកិច្ចនោះ

(ខ) បដិសេធនាវានោះមិនឱ្យប្រើកំពង់ផែរបស់ខ្លួនសម្រាប់ការឡើងផលនេសាទ ការផ្ទេរ ការវេចខ្ចប់និងការកែច្នៃត្រីដែលមិនធ្លាប់បានចូលចតពីមុន និងប្រើសេវាកម្មកំពង់ផែផ្សេងទៀត រួមមានទាំងការចាក់ប្រេងនិងការផ្គត់ផ្គង់សម្ភារៈបរិក្ខា ការថែទាំ និងការឡើងអ៊ូជូសផុល ប្រសិនបើវិធានការទាំងនេះមិនត្រូវបានអនុវត្តចំពោះនាវានោះស្របនឹងកិច្ចព្រមព្រៀងនេះ ដោយរួមបញ្ចូលទាំងមាត្រា ៤ ផង។

២. ទោះបីជាមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះក្តី ភាគីនៃកិច្ចព្រមព្រៀងមិនត្រូវបដិសេធចំពោះ នាវាដែលស្នើប្រើសេវាកម្មកំពង់ផែជាចាំបាច់បំផុតសម្រាប់សុវត្ថិភាព ឬសុខភាពរបស់នាវិក ឬសុវត្ថិភាពរបស់នាវាផ្ទាល់។

៣. គ្មានលក្ខខណ្ឌណាមួយនៅក្នុងកិច្ចព្រមព្រៀងនេះ រារាំងភាគីមួយមិនឱ្យចាត់វិធានការនានា ស្របតាមច្បាប់អន្តរជាតិ ក្នុងការបំពេញបន្ថែមទៅនឹងវិធានការដែលបានបញ្ជាក់នៅក្នុងកថាខណ្ឌទី១ និងទី២នៃមាត្រានេះរួមទាំងវិធានការរដ្ឋម្ចាស់ទង់ជាតិរបស់នាវាដែលបានបញ្ជាក់ពីការស្នើសុំ ឬអ្វីដែលបាននឹងកំពុងអនុញ្ញាត ឬយល់ព្រម ។

## មាត្រា ១៩. ព័ត៌មានឧបាស្រ័យនៅក្នុងរដ្ឋម្ចាស់កំពង់ផែ

១. ភាគីត្រូវរក្សាទុកនូវព័ត៌មានពាក់ព័ន្ធដែលអាចប្រើការបានជាសាធារណៈ និងផ្តល់ព័ត៌មានទាំងនោះទៅតាមការស្នើសុំជាលាយលក្ខណ៍អក្សររបស់ម្ចាស់នាវា ប្រតិបត្តិករនាវា ម្ចាស់ ឬតំណាងនាវាជាមួយ នឹងការឧបាស្រ័យណាមួយដែលបានធ្វើឡើងដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាតិរបស់ខ្លួន ស្តីអំពីវិធានការរដ្ឋម្ចាស់កំពង់ផែដែលទទួលយកដោយភាគី អនុលោមតាមមាត្រា៩ មាត្រា១១ មាត្រា១៣ ឬ មាត្រា១៨ រាប់បញ្ចូលទាំងព័ត៌មានដែលទាក់ទងនឹងសេវាសាធារណៈ ឬស្ថាប័នតុលាការដែលមានស្រាប់ ក៏ដូចជាព័ត៌មានថាតើមានសិទ្ធិស្វែងរកសំណងដោយយោងទៅតាមច្បាប់ និងបទប្បញ្ញត្តិជាតិរបស់ខ្លួន នៅក្នុងហេតុការណ៍នៃការបាត់បង់ ឬខូចខាតដែលកើតមានឡើងដោយការចោទប្រកាន់ណាមួយពីភាគីថាជាសកម្មភាពខុសច្បាប់។

២. ភាគីត្រូវជូនដំណឹងដល់រដ្ឋម្ចាស់ទង់ជាតិ ម្ចាស់នាវា ប្រតិបត្តិករនាវា មេបញ្ជាការឬតំណាងអំពីលទ្ធផលនៃឧបាស្រ័យទាំងនោះឱ្យបានសមស្រប។ ខណៈពេលដែលភាគីផ្សេងទៀត រដ្ឋ ឬអង្គការអន្តរជាតិត្រូវបានជូនដំណឹងពីសេចក្តីសម្រេចពីមុន ដោយអនុលោមតាមមាត្រា៩ មាត្រា១១ មាត្រា១៣ ឬ មាត្រា១៨ ភាគី ត្រូវជូនដំណឹងទៅពួកគេពីការផ្លាស់ប្តូរណាមួយនៅក្នុងការសម្រេចរបស់ខ្លួន។

# ផ្នែកទី ៥. តួនាទីរដ្ឋម្ចាស់ទង់ជាតិ

## មាត្រា ២០. តួនាទីរដ្ឋម្ចាស់ទង់ជាតិ

១. ភាគីនីមួយៗ ត្រូវឱ្យនាវាប្រើទង់ជាតិរបស់ខ្លួន សហការជាមួយរដ្ឋម្ចាស់កំពង់ផែក្នុងការធ្វើអធិការកិច្ច ដោយអនុលោមតាមកិច្ចព្រមព្រៀងនេះ។

២. នៅពេលដែលភាគីមានមូលហេតុច្បាស់លាស់ដែលអាចជឿជាក់បានថា នាវាប្រើទង់ជាតិរបស់ខ្លួនបានចូលរួមប្រព្រឹត្តបទល្មើសនេសាទនេសាទខុសច្បាប់ គ្មានការអនុញ្ញាត និងគ្មានរបាយការណ៍ឬសកម្មភាពពាក់ព័ន្ធផ្សេងទៀតដែលគាំទ្រដល់ការនេសាទខុសច្បាប់ និងកំពុងស្វែងរកការចូលចតនៅរដ្ឋផ្សេងទៀត ភាគីត្រូវស្នើទៅរដ្ឋនោះ ដើម្បីធ្វើអធិការកិច្ចនាវា ឬចាត់វិធានការផ្សេងទៀតឱ្យបានសមស្របទៅនឹងកិច្ចព្រមព្រៀងនេះ។

៣. ភាគីនីមួយៗ ត្រូវលើកទឹកចិត្តឱ្យនាវាដែលប្រើទង់ជាតិរបស់ខ្លួនដើម្បីឡើងផលនេសាទ ផ្ទេរ វេចខ្ចប់ និងកែច្នៃត្រី និងប្រើសេវាកម្មកំពង់ផែផ្សេងទៀតនៅកំពង់ផែនៃរដ្ឋទាំងឡាយដែលកំពុងអនុវត្តវិធានការ ស្របតាមកិច្ចព្រមព្រៀងនេះ។ ភាគីទាំងឡាយត្រូវបានលើកទឹកចិត្តតាមរយៈអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ និងអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ ឱ្យបង្កើតនីតិវិធីត្រឹមត្រូវ មានតម្លាភាព និងមិនរើសអើងក្នុងការកំណត់អត្តសញ្ញាណរដ្ឋណាមួយដែលមិនអនុវត្តតាមឬមានលក្ខណៈមិនស្របនឹងកិច្ចព្រមព្រៀងនេះ។

៤. បន្ទាប់ពីបានទទួលរបាយការណ៍នៃការធ្វើអធិការកិច្ចពីរដ្ឋម្ចាស់កំពង់ផែ ដែលបង្ហាញពីមូលហេតុច្បាស់លាស់ដែលអាចជឿជាក់បានថា នាវាដែលប្រើទង់ជាតិរបស់ខ្លួនបានរួមចំណែកក្នុងការនេសាទខុសច្បាប់ គ្មានការអនុញ្ញាត និងគ្មានរបាយការណ៍ ឬសកម្មភាពពាក់ព័ន្ធផ្សេងទៀតដែលគាំទ្រដល់ការនេសាទខុសច្បាប់ រដ្ឋម្ចាស់ទង់ជាតិនោះត្រូវធ្វើការស៊ើបអង្កេតភ្លាម និងពេញលេញ និងយោងតាមភស្តុតាងគ្រប់គ្រាន់ដើម្បីចាត់វិធានការបង្ក្រាបដោយមិនបង្អែរបង្អង់ស្របតាមច្បាប់ និងបទប្បញ្ញត្តិនានារបស់ខ្លួន។

៥. ភាគីនីមួយៗជារដ្ឋម្ចាស់ទង់ជាតិ ត្រូវរាយការណ៍ទៅភាគីផ្សេងៗ រដ្ឋម្ចាស់កំពង់ផែ និងរដ្ឋពាក់ព័ន្ធផ្សេងទៀត ព្រមទាំងអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ ក៏ដូចជាអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ អំពី

សកម្មភាពខ្លួនដែលបានចាត់វិធានការទាក់ទងនឹងនាវាដែលប្រើទង់ជាតិរបស់ខ្លួន ដែលបានរកឃើញថា នាវានោះបានចូលរួមក្នុងសកម្មភាពនេសាទខុសច្បាប់ គ្មានការអនុញ្ញាត និងគ្មានរបាយការណ៍ឬសកម្មភាពពាក់ព័ន្ធផ្សេងទៀតដែលគាំទ្រដល់ការនេសាទខុសច្បាប់ទាំងនោះ យោងតាមលទ្ធផលនៃការ ចាត់វិធានការពីរដ្ឋម្ចាស់កំពង់ផែដោយអនុលោមតាមកិច្ចព្រមព្រៀងនេះ។

៦. ភាគីនីមួយៗ ត្រូវធានាថា វិធានការនានាដែលបានអនុវត្តចំពោះនាវាដែលប្រើទង់ជាតិរបស់ខ្លួន យ៉ាងហោចណាស់ក៏មានប្រសិទ្ធភាពក្នុងការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានការអនុញ្ញាត និងគ្មានរបាយការណ៍ ឬសកម្មភាពពាក់ព័ន្ធផ្សេងទៀតដែលគាំទ្រដល់ការនេសាទខុសច្បាប់ ដូចវិធានការដែលបានអនុវត្តលើនាវាទាំងនោះ ផ្អែកតាមកថាខណ្ឌទី១នៃមាត្រា ៣។

## ផ្នែកទី ៦. តម្រូវការរដ្ឋកំពុងអភិវឌ្ឍ

### មាត្រា ២១. តម្រូវការរដ្ឋកំពុងអភិវឌ្ឍ

១. ភាគីទាំងអស់ ត្រូវទទួលស្គាល់ពេញលេញ នូវតម្រូវការពិសេសរបស់ភាគីនៃរដ្ឋកំពុងអភិវឌ្ឍទាក់ទងនឹងការអនុវត្តវិធានការរដ្ឋម្ចាស់កំពង់ផែសមស្របនឹងកិច្ចព្រមព្រៀងនេះ។ ហេតុដូច្នេះ ភាគីត្រូវជួយដោយផ្ទាល់ ឬតាមរយៈអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ ភ្នាក់ងារឯកទេសផ្សេងទៀតរបស់អង្គការសហប្រជាជាតិ ឬអង្គការនិងស្ថាប័នអន្តរជាតិសមស្របផ្សេងទៀត រួមទាំងអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ផងដើម្បីជួយដល់រដ្ឋកំពុងអភិវឌ្ឍ៖

(ក) បង្កើនលទ្ធភាពរបស់បណ្តារដ្ឋជាពិសេសរដ្ឋដែលមានការអភិវឌ្ឍតិចតួចនិងរដ្ឋដែលជាដីកោះតូចៗកំពុងអភិវឌ្ឍ ដើម្បីបង្កើនសមត្ថភាពសម្រាប់ការអនុវត្តវិធានការរដ្ឋម្ចាស់កំពង់ផែប្រកបដោយប្រសិទ្ធភាព

(ខ) សម្របសម្រួលដល់ការចូលរួមរបស់បណ្តារដ្ឋទាំងនោះ ជាមួយអង្គការអន្តរជាតិនានាដែលជួយលើកកម្ពស់ប្រសិទ្ធភាពនៃការអភិវឌ្ឍ និងការអនុវត្តវិធានការរដ្ឋម្ចាស់កំពង់ផែ និង

(គ) សម្រួលដល់ការផ្តល់ជំនួយបច្ចេកទេសក្នុងការពង្រឹងការអភិវឌ្ឍ និងការអនុវត្តវិធានការរដ្ឋម្ចាស់កំពង់ផែ ជាមួយយន្តការអន្តរជាតិពាក់ព័ន្ធនានា។

២. ភាគីទាំងឡាយត្រូវយកចិត្តទុកដាក់ទៅលើតម្រូវការពិសេសរបស់រដ្ឋម្ចាស់កំពង់ផែដែលកំពុងអភិវឌ្ឍ ជាពិសេសរដ្ឋអភិវឌ្ឍតិចតួច និងបណ្តារដ្ឋដែលជាដីកោះតូចៗកំពុងអភិវឌ្ឍ ដើម្បីធានាថាបន្ទុកមិនសមាមាត្រមួយ ដែលកើតចេញពីការអនុវត្តកិច្ចព្រមព្រៀងនេះ មិនត្រូវបានផ្ទេរដោយផ្ទាល់ ឬដោយប្រយោលទៅកាន់ពួកគេនោះទេ។ ក្នុងករណីការផ្ទេរបន្ទុកមិនស្មើគ្នាត្រូវបានបង្ហាញ ភាគីត្រូវសហការគ្នាជាមួយភាគីនៃរដ្ឋកំពុងអភិវឌ្ឍពាក់ព័ន្ធដើម្បីសម្រួលដល់ការអនុវត្តកាតព្វកិច្ចជាក់លាក់ ក្រោមកិច្ចព្រមព្រៀងនេះ។

៣. ភាគីត្រូវសិក្សាវាយតម្លៃទៅលើតម្រូវការពិសេសរបស់ភាគីនៃរដ្ឋកំពុងអភិវឌ្ឍដោយផ្ទាល់ ឬតាមរយៈអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ ទាក់ទងនឹងការអនុវត្តកិច្ចព្រមព្រៀងនេះ។

៤. ភាគីត្រូវសហការគ្នាដើម្បីបង្កើតយន្តការផ្តល់មូលនិធិសមស្រប ដើម្បីជួយដល់រដ្ឋកំពុងអភិវឌ្ឍក្នុងការអនុវត្តកិច្ចព្រមព្រៀងនេះ។ យន្តការទាំងនេះ ត្រូវសំដៅផ្តោះទៅកាន់កិច្ចការជាក់លាក់ដែលមានជាអាទិ៍ដូចខាងក្រោម៖

(ក) អភិវឌ្ឍន៍វិធានការរដ្ឋម្ចាស់កំពង់ផែជាតិ និងអន្តរជាតិ

(ខ) អភិវឌ្ឍន៍ និងបង្កើនសមត្ថភាពរួមបញ្ចូលទាំងការតាមដាន ត្រួតពិនិត្យ និងអង្កេតសម្រាប់ការបណ្តុះបណ្តាលនៅថ្នាក់ជាតិ និងតំបន់ចំពោះអ្នកគ្រប់គ្រងកំពង់ផែ មន្ត្រីអធិការកិច្ច មន្ត្រីអនុវត្តច្បាប់ និងមន្ត្រីច្បាប់នានា

(គ) សកម្មភាពតាមដាន ត្រួតពិនិត្យ អង្កេត និងការគោរពតាមច្បាប់ពាក់ព័ន្ធនឹងវិធានការរដ្ឋម្ចាស់កំពង់ផែរួមទាំងការប្រើបច្ចេកវិទ្យា និងឧបករណ៍ផ្សេងៗ

(ឃ) ជួយដល់ភាគីនៃរដ្ឋកំពុងអភិវឌ្ឍ ទាក់ទងនឹងការចំណាយពាក់ព័ន្ធលើកិច្ចដំណើរការណាមួយ ក្នុងការដោះស្រាយវិវាទដែលបណ្ដាលមកពីសកម្មភាពនានាដែលពួកគេបានចាត់វិធាន ការសមស្របតាមកិច្ចព្រមព្រៀងនេះ។

៥. កិច្ចសហប្រតិបត្តិការជាមួយ និងក្នុងចំណោមភាគីនៃរដ្ឋកំពុងអភិវឌ្ឍទាំងឡាយសម្រាប់កំណត់គោលបំណងក្នុងមាត្រានេះ អាចរួមបញ្ចូលទាំងការផ្ដល់ជំនួយបច្ចេកទេស និងហិរញ្ញវត្ថុតាមរយៈបណ្ដាញ ទ្វេភាគី ពហុភាគី និងថ្នាក់តំបន់ រួមទាំងកិច្ចសហប្រតិបត្តិការត្បូង-ត្បូងផង។

៦. ភាគីទាំងឡាយត្រូវបង្កើតក្រុមការងារចំពោះកិច្ច ដើម្បីរាយការណ៍ជាទៀងទាត់តាមកាលកំណត់ និងផ្ដល់អនុសាសន៍ដល់ភាគីនានា ស្ដីពីការបង្កើតយន្តការផ្ដល់មូលនិធិ រួមមានជាទម្រង់មួយសម្រាប់ការចូលរួមវិភាគទាន ការកំណត់ និងការគៀងគរមូលនិធិ ការរៀបចំលក្ខខណ្ឌ និងនីតិវិធី ដើម្បីណែនាំទៅលើការអនុវត្តព្រមទាំងវឌ្ឍនភាពនៃការអនុវត្តយន្តការផ្ដល់មូលនិធិនេះ។ បន្ថែមលើការយកចិត្តទុកដាក់ដូចមានចែងក្នុងមាត្រានេះ ក្រុមការងារចំពោះកិច្ច ត្រូវពិចារណាទៅលើការងារមួយចំនួនទៀត ជាអាទិ៍ដូចខាងក្រោម៖

(ក) ការវាយតម្លៃតម្រូវការរបស់ភាគីនៃរដ្ឋកំពុងអភិវឌ្ឍ ជាពិសេសរដ្ឋអភិវឌ្ឍតិចតួចនិងរដ្ឋកោះតូចៗកំពុងអភិវឌ្ឍ

(ខ) មានមូលនិធិ និងការផ្ដល់ទាន់ពេលវេលា

(គ) តម្លាភាពក្នុងការធ្វើសេចក្ដីសម្រេចចិត្ត និងដំណើរការគ្រប់គ្រងពាក់ព័ន្ធនឹងការគៀងគរ និងការបែងចែកមូលនិធិ

(ឃ) គណនេយ្យភាពនៃអ្នកទទួលមូលនិធិ តាមបណ្ដាភាគីនៃរដ្ឋកំពុងអភិវឌ្ឍក្នុងការព្រមព្រៀងលើការប្រើមូលនិធិ។

ភាគីត្រូវពិចារណាទៅលើរបាយការណ៍ និងអនុសាសន៍របស់ក្រុមការងារចំពោះកិច្ច និងចាត់វិធានការឱ្យបានសមស្រប។

## ផ្នែកទី ៧. ការដោះស្រាយវិវាទ

### មាត្រា ២២. ការដោះស្រាយវិវាទដោយសន្តិវិធី

១. ភាគីណាមួយក៏ដោយអាចស្វែងរកការពិគ្រោះយោបល់ជាមួយភាគីណាមួយផ្សេងទៀត ឬភាគីនានាអំពីវិវាទណាមួយទាក់ទងទៅនឹងការបកស្រាយ ឬចំណុចណាមួយក្នុងបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះជាមួយនឹងទស្សនៈ ដើម្បីឈានដល់ដំណោះស្រាយមួយដែលពេញចិត្តទាំងសងខាងបានឆាប់តាមដែលអាចធ្វើទៅបាន។

២. ក្នុងករណីដែលវិវាទមិនអាចដោះស្រាយបាន តាមរយៈការពិគ្រោះយោបល់ក្នុងអំឡុងពេលសមស្រប ភាគីទំនាស់ត្រូវពិគ្រោះយោបល់រវាងពួកគេឱ្យបានឆាប់ តាមដែលអាចធ្វើទៅបានជាមួយនឹងទស្សនៈឆ្ពោះទៅកាន់ការដោះស្រាយវិវាទដោយការចរចា ការស៊ើបអង្កេត ការសម្រុះសម្រួល ការផ្សះផ្សា ការដោះស្រាយមានអាជ្ញាកណ្ដាលការដោះស្រាយដោយនីតិវិធីតុលាការឬតាមមធ្យោបាយសន្តិវិធីផ្សេងៗទៀតដែលជាជម្រើសរបស់ខ្លួន

៣. វិវាទប្រភេទណាមួយដែលមិនអាចដោះស្រាយបាន ដោយមានការយល់ព្រមពីភាគីទាំងអស់នៃវិវាទ ការកាត់ក្ដីនឹងអាចត្រូវបានបញ្ជូនទៅកាន់តុលាការយុត្តិធម៌អន្តរជាតិ តុលាការអន្តរជាតិស្ដីពីច្បាប់សមុទ្រ ឬអាជ្ញាកណ្ដាលដើម្បីដោះស្រាយ ។ ក្នុងករណីទទួលបរាជ័យក្នុងកិច្ចព្រមព្រៀងលើការបញ្ជូនករណីវិវាទទៅកាន់តុលាការយុត្តិធម៌អន្តរជាតិ តុលាការអន្តរជាតិស្ដីពីច្បាប់សមុទ្រ ឬទៅកាន់អាជ្ញាកណ្ដាល ភាគីទាំងឡាយត្រូវបន្តពិគ្រោះ

យោបល់ និងសហការដោយផ្អែកលើទស្សនៈដែលអាចឈានទៅដល់ការដោះស្រាយវិវាទ ដោយអនុលោមតាមច្បាប់អន្តរជាតិស្តីពីការអភិរក្សធនធានមានជីវិតនៅក្នុងសមុទ្រ។

## ផ្នែកទី ៨. ភាគីមិនមែនជាសមាជិក

### មាត្រា ២៣. ភាគីមិនមែនជាសមាជិកនៃកិច្ចព្រមព្រៀងនេះ

១. ភាគីនៃកិច្ចព្រមព្រៀងទាំងអស់ ត្រូវលើកទឹកចិត្តដល់ភាគីមិនមែនជាសមាជិកឱ្យចូលជាភាគីនៃកិច្ចព្រមព្រៀងនេះ ឬទទួលយកច្បាប់ និងបទប្បញ្ញត្តិនានា ដើម្បីមានវិធានការក្នុងការអនុវត្តស្របជាមួយ នឹងបទប្បញ្ញត្តិរបស់ខ្លួន។

២. ភាគីនៃកិច្ចព្រមព្រៀងទាំងអស់ ត្រូវគោរពគ្នាទៅវិញទៅមក មិនរើសអើង និងមានតម្លាភាពស្របតាមកិច្ចព្រមព្រៀងនេះ និងច្បាប់អន្តរជាតិជាធរមាន ដើម្បីទប់ស្កាត់សកម្មភាពនានារបស់ភាគីមិនមែនជាសមាជិក ដែលអាចធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងនេះ។

## ផ្នែកទី ៩. ការត្រួតពិនិត្យ ការពិនិត្យឡើងវិញ និងការវាយតម្លៃ

### មាត្រា ២៤. ការត្រួតពិនិត្យ ការពិនិត្យឡើងវិញ និងការវាយតម្លៃ

១. ភាគីទាំងឡាយត្រូវធានាបាននូវការត្រួតពិនិត្យជាទៀងទាត់ និងលក្ខណៈជាប្រព័ន្ធ និងពិនិត្យឡើងវិញនូវការអនុវត្តកិច្ចព្រមព្រៀងនេះរួមទាំងការវាយតម្លៃពីភាពរីកចម្រើនឆ្ពោះទៅរកការសម្រេចបាននូវគោលបំណងនៃកិច្ចព្រមព្រៀង ដែលស្ថិតក្នុងក្របខណ្ឌរបស់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ និងស្ថាប័នពាក់ព័ន្ធនានានៃអង្គការនេះ។

២. បន្ទាប់ពីកិច្ចព្រមព្រៀងនេះចូលជាធរមានរយៈពេល៤ឆ្នាំ អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ ត្រូវរៀបចំកិច្ចប្រជុំជាមួយភាគីទាំងអស់ដើម្បីពិនិត្យឡើងវិញ និងវាយតម្លៃពីប្រសិទ្ធភាពនៃការសម្រេចបានតាមគោលបំណងរបស់កិច្ចព្រមព្រៀងនេះ។ ភាគីទាំងអស់ត្រូវសម្រេចចិត្តថានឹងជួបប្រជុំគ្នាបន្តទៀតក្នុងករណីចាំបាច់។

## ផ្នែកទី ១០. អវសានប្បញ្ញត្តិ

### មាត្រា ២៥. ការចុះហត្ថលេខា

កិច្ចព្រមព្រៀងនេះ ត្រូវបានបើកសម្រាប់ការចុះហត្ថលេខានៅអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ ចាប់ពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៩ រហូតដល់ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១០ ដោយប្រទេសទាំងអស់ និងអង្គការសមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់។

### មាត្រា ២៦. ការផ្តល់សច្ចាប័ន ការទទួលយក ឬការយល់ព្រម

១. កិច្ចព្រមព្រៀងនេះ គឺជាកម្មវត្ថុនៃការផ្តល់សច្ចាប័ន ទទួលយក ឬយល់ព្រមដោយហត្ថលេខី។

២. លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលយកឬការយល់ព្រម ត្រូវតម្កល់ទុកនៅកន្លែងអ្នកទទួលបន្ទុកតម្កល់ឯកសារ។

### មាត្រា ២៧. ការចូលជាសមាជិក

១. បន្ទាប់ពីរយៈពេលបើកឱ្យចុះហត្ថលេខារួចមក ការចូលជាសមាជិកនៃកិច្ចព្រមព្រៀងនេះ ពីសំណាក់រដ្ឋ ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់ណាមួយ នៅតែបើកចំហ។

២. លិខិតុបករណ៍នៃការចូលបន្ថែម ត្រូវតម្កល់នៅកន្លែងតម្កល់ឯកសារ។

## មាត្រា ២៨. ការចូលរួមរបស់អង្គការសមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់

១. ដោយផ្អែកលើខ្លឹមសារដែលបានចែងក្នុងឧបសម្ព័ន្ធទី៩ មាត្រា ១ នៃអនុសញ្ញាក្នុងករណីអង្គការសមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់ដែលជាអង្គការអន្តរជាតិ ដែលមិនមានសមត្ថកិច្ចគ្របដណ្តប់ទៅលើគ្រប់បញ្ហាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ ឧបសម្ព័ន្ធទី៩ នៃអនុសញ្ញាត្រូវអនុវត្តនូវជម្រើសដូចគ្នា ដើម្បីឱ្យអង្គការសមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់បានចូលរួមក្នុងកិច្ចព្រមព្រៀងនេះ លើកលែងតែបទប្បញ្ញត្តិ ដូចខាងក្រោមមិនត្រូវបានអនុវត្តទេ៖

(ក) មាត្រា ២ វាក្យខណ្ឌទី១ និង

(ខ) មាត្រា ៣ កថាខណ្ឌទី១។

២. ដោយផ្អែកលើខ្លឹមសារដែលបានចែងក្នុងឧបសម្ព័ន្ធទី៩ មាត្រា ១ នៃអនុសញ្ញាក្នុងករណីអង្គការសមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់ដែលជាអង្គការអន្តរជាតិ មានសមត្ថកិច្ចទៅលើគ្រប់ចំណុចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ បទប្បញ្ញត្តិដូចខាងក្រោមនេះ ត្រូវអនុវត្តចំពោះការចូលរួមរបស់អង្គការ សមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់ក្នុងកិច្ចព្រមព្រៀងនេះ៖

(ក) ក្នុងពេលចុះហត្ថលេខាឬចូលសមាជិកបន្ថែមអង្គការទាំងនោះត្រូវធ្វើសេចក្តីប្រកាសដូចខាងក្រោមថា៖

(i) ខ្លួនមានសមត្ថកិច្ចទៅលើគ្រប់ចំណុចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ

(ii) ដោយហេតុផលថា ប្រទេសសមាជិករបស់ខ្លួនមិនអាចក្លាយជារដ្ឋភាគីបាន លើកលែងតែមានការគោរពដែនអធិបតេយ្យរបស់រដ្ឋទាំងនោះ ដែលអង្គការនេះគ្មានការទទួលខុសត្រូវឡើយ

(iii) ខ្លួនយល់ព្រមគោរពសិទ្ធិ និងកាតព្វកិច្ចរបស់រដ្ឋនៃកិច្ចព្រមព្រៀងនេះ។

(ខ) ការចូលរួមរបស់អង្គការណាមួយបែបនេះនឹងមិនមានករណីផ្តល់សិទ្ធណាមួយក្នុងកិច្ចព្រមព្រៀងទៅលើរដ្ឋជាសមាជិកនៃអង្គការនេះ

(គ) ក្នុងករណីមានវិវាទរវាងកាតព្វកិច្ចរបស់អង្គការក្រោមកិច្ចព្រមព្រៀងនេះនិងកាតព្វកិច្ចរបស់ខ្លួនក្រោមកិច្ចព្រមព្រៀងក្នុងការបង្កើតអង្គការ ឬសកម្មភាពណាមួយដែលពាក់ព័ន្ធ កាតព្វកិច្ចដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ ត្រូវយកជាគោល។

## មាត្រា ២៩. ការចូលជាធរមាន

១. កិច្ចព្រមព្រៀងនេះ ត្រូវចូលជាធរមាន៣០(សាមសិប)ថ្ងៃ ក្រោយពីថ្ងៃប្រគល់ឯកសារឱ្យអ្នកទទួលបន្ទុកតម្កល់ឯកសារនូវលិខិតុបករណ៍ទី២៥ (ម្ភៃប្រាំ) នៃការផ្តល់សច្ចាប័ន ការទទួលយក ការយល់ព្រម ឬការចូលបន្ថែមអនុលោមទៅតាមមាត្រា ២៦ ឬមាត្រា ២៧។

២. សម្រាប់បណ្តាប្រទេសហត្ថលេខីដែលផ្តល់សច្ចាប័ន ទទួលយក ឬយល់ព្រមកិច្ចព្រមព្រៀងនេះ ក្រោយពីកិច្ចព្រមព្រៀងចូលជាធរមាន កិច្ចព្រមព្រៀងនេះ ត្រូវចូលជាធរមាន៣០(សាមសិប)ថ្ងៃ បន្ទាប់ពីថ្ងៃតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលយក ឬការយល់ព្រម ។

៣. ចំពោះរដ្ឋនីមួយៗ ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់ ដែលឯកភាពយល់ព្រមតាមកិច្ចព្រមព្រៀងបន្ទាប់ពីចូលជាធរមាន កិច្ចព្រមព្រៀងនេះត្រូវចូលជាធរមាន៣០ថ្ងៃ បន្ទាប់ពីថ្ងៃដាក់តម្កល់លិខិតុបករណ៍នៃការចូលរួម។

៤. ក្នុងគោលបំណងនៃមាត្រានេះ លិខិតុបករណ៍ណាមួយដែលយកមកតម្កល់ដោយអង្គការសមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់ មិនត្រូវបានរាប់បញ្ចូលជាឯកសារបន្ថែមដែលតម្កល់ទុកដោយរដ្ឋសមាជិកឡើយ។

## មាត្រា ៣០. ការបម្រុងទុក និងការលើកលែង

គ្មានការបម្រុងទុក ឬការលើកលែង ត្រូវបានធ្វើឡើងក្នុងកិច្ចព្រមព្រៀងនេះឡើយ។

## មាត្រា ៣១. សេចក្តីប្រកាស និងសេចក្តីថ្លែងការណ៍

មាត្រា ៣០ មិនបានរារាំងដល់រដ្ឋ ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់ពីការធ្វើសេចក្តីប្រកាស ឬសេចក្តីថ្លែងការណ៍ខណៈពេលចុះហត្ថលេខា ផ្តល់សច្ចាប័ន ទទួលយក យល់ព្រម ឬការចូលជាសមាជិកនៃកិច្ចព្រមព្រៀងនេះ តែទោះជាយ៉ាងណាក៏ដោយ ការដាក់ឃ្លា ឬឈ្មោះជាមួយនឹងទស្សនៈ ជាអាទិ៍ ការធ្វើឱ្យមានស្តង់ដារួមនៃច្បាប់ និងបទប្បញ្ញត្តិរបស់ខ្លួនជាមួយនឹងបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ត្រូវបញ្ជាក់ពីការប្រកាស ឬសេចក្តីថ្លែងការណ៍បែបនេះ ថាមិនមានបំណងដកចេញ ឬកែប្រែប្រសិទ្ធភាពស្របច្បាប់នៃបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ក្នុងការអនុវត្តកម្មវិធីរបស់រដ្ឋ ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់នោះទេ។

## មាត្រា ៣២. ការអនុវត្តបណ្តោះអាសន្ន

១. កិច្ចព្រមព្រៀងនេះ នឹងត្រូវដាក់ឱ្យអនុវត្តជាបណ្តោះអាសន្នដោយរដ្ឋ ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់ ដែលយល់ព្រមទៅលើការអនុវត្តបណ្តោះអាសន្នសម្រាប់អនុវត្តដោយជូនដំណឹងជាលាយល័ក្ខអក្សរទៅអ្នកទទួលខុសត្រូវតម្កល់ឯកសារ។ ការអនុវត្តបណ្តោះអាសន្ននេះ ត្រូវចូលជាធរមាន ចាប់ពីថ្ងៃទទួលសេចក្តីជូនដំណឹងនេះតទៅ។

២. ការអនុវត្តបណ្តោះអាសន្នរបស់រដ្ឋ ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់ត្រូវបញ្ចប់ អាស្រ័យលើការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ សម្រាប់រដ្ឋឬអង្គការសមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់ ឬអាស្រ័យលើសេចក្តីជូនដំណឹងជាលាយល័ក្ខអក្សរទៅអ្នកទទួលបន្ទុកតម្កល់ឯកសារ ដោយបញ្ជាក់ពីគោលបំណងនៃការបញ្ចប់ការអនុវត្តបណ្តោះអាសន្នរបស់ខ្លួន។

## មាត្រា ៣៣. វិសោធនកម្ម

១. រាល់ភាគីអាចស្នើធ្វើវិសោធនកម្មកិច្ចព្រមព្រៀងនេះបាន បន្ទាប់ពីផុតសុពលភាពរយៈពេល២ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ។

២. រាល់ការស្នើធ្វើវិសោធនកម្មកិច្ចព្រមព្រៀងនេះ ត្រូវបញ្ជូនជាលាយល័ក្ខអក្សរទៅកាន់អ្នកទទួលបន្ទុកតម្កល់ឯកសារ រួមជាមួយនឹងសំណើរៀបចំកិច្ចប្រជុំរបស់ភាគីនានា ដើម្បីពិភាក្សាទៅលើការស្នើសុំនេះ។ អ្នកទទួលបន្ទុកតម្កល់ឯកសារ នឹងចែកចាយដល់គ្រប់ភាគី ទាំងការទំនាក់ទំនងក៏ដូចជាការឆ្លើយតប ទៅនឹងការស្នើសុំដែលទទួលបានពីគ្រប់ភាគីទាំងអស់។ លើកលែងតែចំនួនពាក់កណ្តាលនៃភាគីទាំងអស់ ជំទាស់ទៅនឹងការស្នើសុំក្នុងរយៈពេល៦ខែ បន្ទាប់ពីថ្ងៃចែកចាយ និងការទំនាក់ទំនង អ្នកទទួលបន្ទុកតម្កល់ឯកសារត្រូវបើកកិច្ចប្រជុំ ដោយកោះអញ្ជើញភាគីទាំងអស់ដើម្បីពិចារណាលើសំណើសុំវិសោធនកម្ម។

៣. យោងតាមមាត្រា ៣៤ រាល់ការធ្វើវិសោធនកម្មកិច្ចព្រមព្រៀងនេះ ត្រូវទទួលបានការអនុម័តដោយ មានការមូលមតិជាឯកច្ឆន្ទពីភាគីដែលមានវត្តមានក្នុងកិច្ចប្រជុំ អំឡុងពេលស្នើឡើងដើម្បីអនុម័ត។

៤. យោងតាមមាត្រា ៣៤ រាល់វិសោធនកម្មដែលបានអនុម័តដោយកិច្ចប្រជុំរវាងភាគីទាំងអស់ ត្រូវចូលជាធរមានក្នុងចំណោមភាគីដែលបានផ្តល់សច្ចាប័នទទួលយក ឬអនុម័តក្នុងអំឡុងពេល៩០ថ្ងៃ បន្ទាប់ពីការដាក់លិខិតុបករណ៍នៃការផ្តល់សច្ចាប័នទទួលយក ឬយល់ព្រមពីរភាគបី (២/៣) នៃចំនួនភាគីដែលបានចូលរួមក្នុងថ្ងៃអនុម័តលើការធ្វើវិសោធនកម្មនេះ។ បន្ទាប់មក វិសោធនកម្មនេះត្រូវចូលជាធរមានសម្រាប់ភាគីដទៃទៀតក្នុងអំឡុងពេល៩០ថ្ងៃ បន្ទាប់ពីភាគីទាំងនោះដាក់លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ទទួលយក ឬយល់ព្រមការធ្វើវិសោធនកម្ម។

៥. ក្នុងគោលបំណងនៃមាត្រានេះ លិខិតុបករណ៍ដែលដាក់តម្កល់ដោយអង្គការសមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់ មិនត្រូវបានរាប់បញ្ចូលបន្ថែមទៅក្នុងការដាក់តម្កល់របស់រដ្ឋជាសមាជិកនៃកិច្ចព្រមព្រៀងនេះទេ។

**មាត្រា ៣៤. ឧបសម្ព័ន្ធ**

១. ឧបសម្ព័ន្ធទាំងអស់បង្កើតជាផ្នែកនៃកិច្ចព្រមព្រៀងនេះ ហើយរាល់ការប្រើជាឯកសារយោងត្រូវជាមូលដ្ឋានភ្ជាប់ជាមួយឧបសម្ព័ន្ធទាំងនោះ។

២. ការធ្វើវិសោធនកម្មឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងនេះ អាចនឹងត្រូវបានអនុម័តដោយមានសម្លេងពីរភាគបី(២/៣) នៃចំនួនភាគីដែលបានចូលរួមក្នុងកិច្ចប្រជុំកែសម្រួលឧបសម្ព័ន្ធ ត្រូវបានលើកយកមកពិនិត្យពិភាក្សា។ ទោះជាយ៉ាងណាក៏ដោយកិច្ចប្រឹងប្រែងទាំងអស់ ត្រូវបានធ្វើឡើងដើម្បីឈានដល់ការព្រមព្រៀងលើវិសោធនកម្មណាមួយលើឧបសម្ព័ន្ធតាមរបៀបនៃការមូលមតិគ្នាជាឯកច្ឆន្ទ។ ការធ្វើវិសោធនកម្មឧបសម្ព័ន្ធត្រូវដាក់បញ្ចូលទៅក្នុងកិច្ចព្រមព្រៀងនេះ និងចូលជាធរមានសម្រាប់ភាគីដែលឯកភាពលើការកែសម្រួលចាប់ពីថ្ងៃដែលអ្នកទទួលបន្ទុកតម្កល់ឯកសារទទួលបានឯកសារយល់ព្រម ដែលមានសម្លេងចាប់ពីមួយភាគបី (១/៣) នៃអ្នកចូលរួមក្នុងថ្ងៃអនុម័តលើការធ្វើវិសោធនកម្ម។ វិសោធនកម្មនេះ ត្រូវចូលជាធរមានជាបន្តបន្ទាប់សម្រាប់ភាគីដែលនៅសល់ អាស្រ័យទៅនឹងការទទួលបានលិខិតទទួលយក ដែលផ្ញើមកអ្នកទទួលបន្ទុកតម្កល់ឯកសារ។

**មាត្រា ៣៥. ការដកខ្លួនចេញ**

ភាគីណាក៏ដោយអាចដកខ្លួនចេញពីកិច្ចព្រមព្រៀងនេះគ្រប់ពេល បន្ទាប់ពី១ឆ្នាំក្រោយនៃការផុតសុពលភាពកិច្ចព្រមព្រៀង គិតចាប់ពីថ្ងៃដែលកិច្ចព្រមព្រៀងនេះចូលជាធរមានដោយសរសេរបញ្ជាក់ជាលាយល័ក្ខអក្សរទៅអ្នកទទួលបន្ទុកតម្កល់ឯកសារ។ ការដកខ្លួនចេញនឹងមានប្រសិទ្ធភាព១ឆ្នាំ ក្រោយពីអ្នកទទួលបន្ទុកតម្កល់ឯកសារទទួលបានលិខិតដកខ្លួនចេញ។

**មាត្រា ៣៦. អ្នកតម្កល់ឯកសារ**

អគ្គនាយកនៃអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិគឺជាអ្នកទទួលបន្ទុកតម្កល់ឯកសារកិច្ចព្រមព្រៀងនេះ។ អ្នកទទួលបន្ទុកតម្កល់ឯកសារត្រូវ៖

(ក) បញ្ជូនច្បាប់ចម្លងនៃកិច្ចព្រមព្រៀងទៅប្រទេសហត្ថលេខី និងភាគីទាំងអស់

(ខ) ចុះបញ្ជីកិច្ចព្រមព្រៀងនេះ បន្ទាប់ពីចូលជាធរមាននៅក្នុងលេខាធិការដ្ឋាននៃអង្គការសហប្រជាជាតិ ដោយអនុលោមតាមមាត្រា ១០២ នៃធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ

(គ) ជូនដំណឹងភ្លាមៗដល់ប្រទេសហត្ថលេខី និងភាគីនៃកិច្ចព្រមព្រៀងទាំងអស់អំពី៖

- (i) ហត្ថលេខា និងលិខិតុបករណ៍នៃការបានផ្តល់សច្ចាប័ន ការទទួលយក ការយល់ព្រម និងការចូលបន្តដែលបានដាក់តម្កល់ស្របតាមមាត្រា ២៥ មាត្រា ២៦ និងមាត្រា ២៧
- (ii) កាលបរិច្ឆេទនៃការចូលជាធរមាននៃកិច្ចព្រមព្រៀង ដោយអនុលោមតាមមាត្រា ២៩
- (iii) សំណើសុំធ្វើវិសោធនកម្មកិច្ចព្រមព្រៀងនេះ និងការអនុម័ត ព្រមទាំងការចូលជាធរមានដោយអនុលោមតាមមាត្រា ៣៣
- (iv) សំណើធ្វើវិសោធនកម្មឧបសម្ព័ន្ធ ការអនុម័ត និងការចូលជាធរមានដោយអនុលោមតាមមាត្រា៣៤
- (v) ការដកខ្លួនចេញពីកិច្ចព្រមព្រៀង ដោយអនុលោមតាមមាត្រា ៣៥។

## ឧបសម្ព័ន្ធ គ. ព័ត៌មានដែលត្រូវផ្តល់ជាមុនដោយនាវាដែលស្នើសុំការចូលចតនៅកំពង់ផែ

<table>
<tr><td colspan="5">១. កំពង់ផែគោលដៅសុំចូលចត</td><td colspan="4"></td></tr>
<tr><td colspan="5">២. រដ្ឋម្ចាស់កំពង់ផែ</td><td colspan="4"></td></tr>
<tr><td colspan="5">៣. កាលបរិច្ឆេទ និងពេលវេលាប៉ាន់ស្មាននៃការមកដល់</td><td colspan="4"></td></tr>
<tr><td colspan="5">៤. គោលបំណង</td><td colspan="4"></td></tr>
<tr><td colspan="5">៥. កំពង់ផែ និងកាលបរិច្ឆេទដែលបានចូលចតចុងក្រោយ</td><td colspan="4"></td></tr>
<tr><td colspan="5">៦. ឈ្មោះនាវា</td><td colspan="4"></td></tr>
<tr><td colspan="5">៧. រដ្ឋម្ចាស់ទង់ជាតិ</td><td colspan="4"></td></tr>
<tr><td colspan="5">៨. ប្រភេទនាវា</td><td colspan="4"></td></tr>
<tr><td colspan="5">៩. សញ្ញាហៅចេញទៅអន្តរជាតិតាមវិទ្យុទាក់ទង</td><td colspan="4"></td></tr>
<tr><td colspan="5">១០. ព័ត៌មានសម្រាប់ទំនាក់ទំនងនាវា</td><td colspan="4"></td></tr>
<tr><td colspan="5">១១. ម្ចាស់នាវា</td><td colspan="4"></td></tr>
<tr><td colspan="5">១២. វិញ្ញាបនប័ត្របញ្ជាក់អត្តសញ្ញាណការចុះបញ្ជី</td><td colspan="4"></td></tr>
<tr><td colspan="5">១៣. លេខសម្គាល់នាវា IMO ប្រសិនបើមាន</td><td colspan="4"></td></tr>
<tr><td colspan="5">១៤. លេខសម្គាល់ខាងក្រៅប្រសិនបើមាន</td><td colspan="4"></td></tr>
<tr><td colspan="5">១៥. លេខសម្គាល់អង្គការគ្រប់គ្រងជលផលថ្នាក់តំបន់</td><td colspan="4"></td></tr>
<tr><td colspan="2">១៦. ប្រព័ន្ធត្រួតពិនិត្យនាវា (VMS)</td><td>គ្មាន</td><td>មាន៖ ថ្នាក់ជាតិ</td><td colspan="2">មាន៖ អង្គការគ្រប់គ្រងជលផលថ្នាក់តំបន់</td><td colspan="3">ប្រភេទ៖</td></tr>
<tr><td colspan="2">១៧.វិមាត្រនាវា</td><td>បណ្ដោយ</td><td colspan="2">ទទឹង</td><td colspan="4">ជម្រៅទឹករបស់នាវាអាចរាចរបាន</td></tr>
<tr><td colspan="3">១៨. ឈ្មោះមេបញ្ជាការនាវានិងសញ្ជាតិ</td><td colspan="6"></td></tr>
<tr><td colspan="9">១៩. ការអនុញ្ញាតនានាក្នុងការនេសាទ</td></tr>
<tr><td colspan="2">អ្នកកំណត់</td><td>ចេញ</td><td colspan="2">សុពលភាព</td><td>កន្លែងធ្វើ</td><td colspan="2">ប្រភេទត្រី</td><td>ឧបករណ៍</td></tr>
<tr><td colspan="2"></td><td></td><td colspan="2"></td><td></td><td colspan="2"></td><td></td></tr>
<tr><td colspan="2"></td><td></td><td colspan="2"></td><td></td><td colspan="2"></td><td></td></tr>
<tr><td colspan="9">២០. ការអនុញ្ញាតលើការផ្ទេរ</td></tr>
<tr><td>អ្នកកំណត់</td><td></td><td colspan="3">ចេញដោយ</td><td></td><td colspan="2">សុពលភាព</td><td></td></tr>
<tr><td>អ្នកកំណត់</td><td></td><td colspan="3">ចេញដោយ</td><td></td><td colspan="2">សុពលភាព</td><td></td></tr>
<tr><td colspan="9">២១. ព័ត៌មានពីការផ្ទេរដែលទាក់ទងនាវាផ្តល់ជំនួយ</td></tr>
<tr><td>កាលបរិច្ឆេទ</td><td>ទីកន្លែង</td><td>ឈ្មោះ</td><td>រដ្ឋម្ចាស់ទង់ជាតិ</td><td>អត្តលេខ</td><td>ប្រភេទត្រី</td><td>ទម្រង់ផលិតផល</td><td>កន្លែងចាប់</td><td>បរិមាណ</td></tr>
<tr><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td></tr>
<tr><td colspan="5">២២. ផលនេសាទសរុបនៅលើនាវា</td><td colspan="4">២៣. ផលចាប់ដែលដាក់ចុះ:</td></tr>
<tr><td>ប្រភេទត្រី</td><td colspan="2">ទម្រង់ផលិតផល</td><td colspan="2">កន្លែងចាប់</td><td colspan="2">បរិមាណ</td><td colspan="2">បរិមាណ</td></tr>
<tr><td></td><td colspan="2"></td><td colspan="2"></td><td colspan="2"></td><td colspan="2"></td></tr>
</table>

## ឧបសម្ព័ន្ធ ខ. នីតិវិធីនៃអធិការកិច្ចរដ្ឋម្ចាស់កំពង់ផែ

អធិការត្រូវ៖

(ក) បញ្ជាក់ថាឯកសារកំណត់អត្តសញ្ញាណនាវានៅលើនាវា និងព័ត៌មានទាក់ទងទៅនឹងម្ចាស់នាវា ពិតជាត្រឹមត្រូវពិតប្រាកដ និងពេញលេញ រួមទាំងការទំនាក់ទំនងសមស្របជាមួយនឹងរដ្ឋម្ចាស់ទង់ជាតិ ឬកំណត់ត្រានាវាអន្តរជាតិ ក្នុងករណីចាំបាច់តាមលទ្ធភាពដែលអាចធ្វើបាន

(ខ) បញ្ជាក់ថាទង់ជាតិដែលប្រើនៅលើនាវា និងសញ្ញាសម្គាល់នាវា(ឧទាហរណ៍៖ ឈ្មោះ លេខ ចុះបញ្ជីនៅខាងក្រៅ លេខសម្គាល់អត្តសញ្ញាណនាវារបស់អង្គការសមុទ្រអន្តរជាតិ សញ្ញាហៅចេញទៅអន្តរជាតិ និងសញ្ញាសំគាល់ផ្សេងទៀត និងវិមាត្រសំខាន់ៗ) គឺស្របជាមួយនឹងព័ត៌មានដែលមាននៅក្នុងឯកសារនេះ

(គ) បញ្ជាក់តាមលទ្ធភាពដែលអាចធ្វើទៅបានថាអាជ្ញាប័ណ្ណសម្រាប់ការនេសាទ និងសកម្មភាពពាក់ព័ន្ធការនេសាទ ពិតជាត្រឹមត្រូវពិតប្រាកដ និងពេញលេញ និងស្របជាមួយព័ត៌មានដែលបានផ្តល់ឱ្យដោយអនុលោមទៅតាមឧបសម្ព័ន្ធ "ក"

(ឃ) ពិនិត្យឯកសារ និងកំណត់ត្រាពាក់ព័ន្ធនៅលើនាវាឡើងវិញទាំងអស់ រួមបញ្ចូលទាំងឯកសារនៅក្នុងប្រព័ន្ធអេឡិចត្រូនិច និងប្រព័ន្ធត្រួតពិនិត្យនាវា (VMS) ទិន្នន័យមកពីរដ្ឋម្ចាស់ទង់ជាតិ ឬអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ដែលពាក់ព័ន្ធនានា (RFMOs) តាមលទ្ធភាពដែលអាចធ្វើបាន។ កំណត់ត្រាពាក់ព័ន្ធអាចមានដូចជាសៀវភៅកំណត់ត្រាបរិមាណផលនេសាទ ការផ្ទេរ និងឯកសារពាណិជ្ជកម្ម បញ្ជីនាវិក ឃ្លុបផ្ទុកទំនិញ និងប្លង់នាវា ការរៀបរាប់អំពីឃ្លុបដាក់ត្រី និងឯកសារចាំបាច់មួយចំនួនដែលទាក់ទងនឹងអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ រុក្ខជាតិ ព្រៃដែលងាយរងគ្រោះ និងជិតផុតពូជ

(ង) ពិនិត្យឧបករណ៍នេសាទពាក់ព័ន្ធទាំងអស់នៅលើនាវា រួមមានឧបករណ៍ដែលបានលាក់ទុក ដោយអាថ៌កំបាំង ព្រមទាំងឧបករណ៍ពាក់ព័ន្ធផ្សេងៗទៀត តាមលទ្ធភាពដែលអាចធ្វើបាន និងត្រូវបញ្ជាក់ថាឧបករណ៍ទាំងនោះស្របតាមលក្ខខណ្ឌដែលបានអនុញ្ញាត។ ឧបករណ៍នេសាទត្រូវបានត្រួតពិនិត្យ ដើម្បីធានាថា រាល់សណ្ឋានដូចជា ទំហំ ក្រឡា និងខ្សែ ព្រមទាំងឧបករណ៍ និងតំណភ្ជាប់ ទំហំ និងរូបរាងសំណាញ់ឃ្លុប ជងស្ទូច ទំហំ និងចំនួនផ្លែសន្ទូច គោរពតាមបទប្បញ្ញត្តិពាក់ព័ន្ធ និងធានាថា សញ្ញាសំគាល់ទាំងនោះឆ្លើយតបទៅនឹងការអនុញ្ញាតសម្រាប់នាវាតាមលទ្ធភាពដែលអាចធ្វើបាន

(ច) កំណត់តាមលទ្ធភាពដែលអាចធ្វើបានថា ផលនេសាទនៅលើនាវាត្រូវបាននេសាទស្របតាមលិខិតអនុញ្ញាតពាក់ព័ន្ធ

(ឆ) ពិនិត្យមើលត្រីតាមរយៈការយកសំណាក ដើម្បីធ្វើការកំណត់នូវបរិមាណ និងសមាសភាគរបស់វា។ ក្នុងសកម្មភាពពិនិត្យនេះ អធិការអាចបើកធុងត្រីដែលបានវេចខ្ចប់រួចហើយ និងអាចផ្លាស់ទីត្រី ឬធុងត្រីទាំងនោះ ដើម្បីអះអាងពីភាពត្រឹមត្រូវរបស់ត្រីនៅក្នុងធុង។ ការពិនិត្យបែបនេះអាចរួមបញ្ចូលការធ្វើអធិការកិច្ចប្រភេទផលិតផល និងការកំណត់ទម្ងន់ជាក់លាក់

(ជ) វាយតម្លៃថាមានភស្តុតាងច្បាស់លាស់ដែរឬទេ សម្រាប់ជាការផ្តល់ការជឿជាក់ថានាវានេសាទបាននឹងកំពុងចូលរួមក្នុងសកម្មភាពនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ឬក្នុងសកម្មភាពពាក់ព័ន្ធផ្សេងទៀតដែលគាំទ្រដល់ការនេសាទខុសច្បាប់

(ឈ) ផ្តល់របាយការណ៍ជូនមេបញ្ជាការនាវានូវលទ្ធផលនៃការធ្វើអធិការកិច្ច រួមបញ្ចូលទាំងវិធានការចាំបាច់ដែលអាចនឹងអនុវត្តដោយមានចុះហត្ថលេខាពីមន្ត្រីអធិការកិច្ច និងមេបញ្ជាការនាវា។ ហត្ថលេខារបស់មេបញ្ជាការនាវានៅលើរបាយការណ៍ គ្រាន់តែជាការទទួលស្គាល់ថាបានទទួលរបាយការណ៍តែប៉ុណ្ណោះ។

មេបញ្ជាការនាវាត្រូវបានអនុញ្ញាតឱ្យបន្ថែមមតិយោបល់ ឬមតិជំទាស់ណាមួយទៅក្នុងរបាយការណ៍នេះ ដោយអ្នកគ្រប់គ្រងអាចទាក់ទងទៅអាជ្ញាធរពាក់ព័ន្ធដែលជារដ្ឋម្ចាស់ទង់ជាតិ ក្នុងករណីអ្នកគ្រប់គ្រងជួបការពិបាកខ្លាំងក្នុងការស្វែងយល់អំពីខ្លឹមសារនៃរបាយការណ៍។ របាយការណ៍ត្រូវផ្តល់ឱ្យមេបញ្ជាការនាវាចំនួនមួយច្បាប់

(៣) រៀបចំចាត់ចែង បកប្រែឯកសារពាក់ព័ន្ធតាមភាពចាំបាច់និងអាចធ្វើទៅបាន។

## ឧបសម្ព័ន្ធ គ. របាយការណ៍លទ្ធផលនៃការធ្វើអធិការកិច្ច

| | | | | | | |
|---|---|---|---|---|---|---|
| ១. លេខរបាយការណ៍អធិការកិច្ច | | | | ២. រដ្ឋម្ចាស់ | | |
| ៣. អាជ្ញាធរត្រួតពិនិត្យ | | | | | | |
| ៤.ឈ្មោះនាយអធិការ | | | | អត្តលេខ | | |
| ៥. កំពង់ផែត្រួតពិនិត្យ | | | | | | |
| ៦. ការចាប់ផ្តើមការត្រួតពិនិត្យ | | | ម៉ោង | ថ្ងៃ | ខែ | ឆ្នាំ |
| ៧. ការបញ្ចប់ការត្រួតពិនិត្យ | | | ម៉ោង | ថ្ងៃ | ខែ | ឆ្នាំ |
| ៨. ទទួលបានការជូនដំណឹងជាមុន | | | បាទ/ចាស | | ទេ | |
| ៩. គោលបំណង | ផែឡើងត្រី | | ផ្ទេរផលនេសាទ | ផលិតផល | | ផ្សេងៗ |
| ១០. ផែ និងរដ្ឋ និងថ្ងៃចូលចត ចុងក្រោយ | | | | ថ្ងៃ | ខែ | ឆ្នាំ |
| ១១. ឈ្មោះនាវា | | | | | | |
| ១២. រដ្ឋម្ចាស់ទង់ជាតិ | | | | | | |
| ១៣. ប្រភេទនាវា | | | | | | |
| ១៤. សញ្ញាហៅចេញទៅអន្តរជាតិ តាមវិទ្យុទាក់ទង | | | | | | |
| ១៥. វិញ្ញាបនបត្រចុះបញ្ជី អត្តសញ្ញាណ | | | | | | |
| ១៦.អត្តសញ្ញាណកប៉ាល់ IMO ប្រសិនបើមាន | | | | | | |
| ១៧. លេខសម្គាល់ខាងក្រៅ ប្រសិនបើមាន | | | | | | |
| ១៨. កំពង់ផែចុះបញ្ជី | | | | | | |
| ១៩. ម្ចាស់នាវា | | | | | | |
| ២០. ម្ចាស់ទទួលផលពីនាវា ប្រសិនបើស្គាល់ និង ខុសពីម្ចាស់នាវា | | | | | | |
| ២១. ប្រតិបត្តិករនាវា ប្រសិនបើ ខុសពីម្ចាស់នាវា | | | | | | |
| ២២. ឈ្មោះ និងសញ្ជាតិមេបញ្ជាការ នាវា | | | | | | |
| ២៣. ឈ្មោះ និងសញ្ជាតិមេដឹកនាំការនេសាទ | | | | | | |
| ២៤. ភ្នាក់ងារនាវា | | | | | | |
| ២៥. ប្រព័ន្ធត្រួតពិនិត្យនាវា | ទេ | | មាន៖ ថ្នាក់ជាតិ | មាន៖ អង្គការគ្រប់គ្រងផលផលថ្នាក់តំបន់ | | ប្រភេទ៖ |
| ២៦. ស្ថានភាពនៅក្នុងតំបន់អង្គការគ្រប់គ្រងផលផលថ្នាក់តំបន់ដែលជាកន្លែងនេសាទ ឬសកម្មភាពនានាទាក់ទងនឹងការនេសាទត្រូវបានអនុវត្ត រួមទាំងបញ្ជីនាវានេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត | | | | | | |
| អ្នកកំណត់នាវា | អង្គការគ្រប់គ្រងផលផលថ្នាក់តំបន់ | | ស្ថានភាពរដ្ឋម្ចាស់ទង់ជាតិ | នាវាស្ថិតក្នុងបញ្ជីនាវាអនុញ្ញាត | | នាវានៅក្នុងបញ្ជីនាវា IUU |
| | | | | | | |
| | | | | | | |
| ២៧. លិខិតអនុញ្ញាតធ្វើនេសាទពាក់ព័ន្ធ | | | | | | |
| អ្នកកំណត់ | ចេញដោយ | | សុពលភាព | កន្លែងធ្វើនេសាទ | ប្រភេទត្រី | ឧបករណ៍ |
| | | | | | | |
| | | | | | | |
| ២៨. លិខិតអនុញ្ញាតផ្ទេរពាក់ព័ន្ធ | | | | | | |
| អ្នកកំណត់ | | ចេញដោយ | | សុពលភាព | | |
| អ្នកកំណត់ | | ចេញដោយ | | សុពលភាព | | |
| ២៩. ព័ត៌មានការផ្ទេរទាក់ទងនឹងនាវាផ្តល់ជំនួយ | | | | | | |
| ឈ្មោះ | រដ្ឋម្ចាស់ទង់ជាតិ | លេខ ID | ប្រភេទត្រី | ទម្រង់ផលិតផល | កន្លែងចាប់ | បរិមាណ |

<table>
<tr><td></td><td></td><td></td><td></td><td></td><td></td><td></td></tr>
<tr><td></td><td></td><td></td><td></td><td></td><td></td><td></td></tr>
<tr><td colspan="7">៣០. ការវាយតម្លៃនៃការឡើងផលនេសាទ (បរិមាណ)</td></tr>
<tr><td>ប្រភេទត្រី</td><td>ទម្រង់ផលិតផល</td><td>កន្លែងចាប់</td><td>បរិមាណបានប្រកាស</td><td>បរិមាណជាក់ចុះ</td><td colspan="2">ភាពខុសគ្នារវាងបរិមាណ បានប្រកាសនិងបរិមាណជាក់ស្តែង ប្រសិនបើមាន</td></tr>
<tr><td></td><td></td><td></td><td></td><td></td><td colspan="2"></td></tr>
<tr><td></td><td></td><td></td><td></td><td></td><td colspan="2"></td></tr>
<tr><td colspan="7">៣១. ផលចាប់បានរក្សាទុកនៅលើនាវា</td></tr>
<tr><td>ប្រភេទត្រី</td><td>ទម្រង់ផលិតផល</td><td>កន្លែងចាប់</td><td>បរិមាណបានប្រកាស</td><td>បរិមាណបានរក្សាទុក</td><td colspan="2">ភាពខុសគ្នារវាងបរិមាណបានប្រកាស និងបរិមាណជាក់ស្តែង ប្រសិនបើមាន</td></tr>
<tr><td></td><td></td><td></td><td></td><td></td><td colspan="2"></td></tr>
<tr><td></td><td></td><td></td><td></td><td></td><td colspan="2"></td></tr>
<tr><td colspan="3">៣២. ការពិនិត្យសៀវភៅកត់ត្រា (logbook) និងឯកសារផ្សេងទៀត</td><td>បាទ/ចាស</td><td>ទេ</td><td colspan="2">យោបល់</td></tr>
<tr><td colspan="3">៣៣. ការគោរពតាមប្រព័ន្ធគ្រប់គ្រងផលនេសាទ</td><td>បាទ/ចាស</td><td>ទេ</td><td colspan="2">យោបល់</td></tr>
<tr><td colspan="3">៣៤. ការគោរពតាមប្រព័ន្ធគ្រប់គ្រងព័ត៌មានពាណិជ្ជកម្មពាក់ព័ន្ធ</td><td>បាទ/ចាស</td><td>ទេ</td><td colspan="2">យោបល់</td></tr>
<tr><td colspan="3">៣៥.ប្រភេទឧបករណ៍ដែលប្រើ</td><td colspan="4"></td></tr>
<tr><td colspan="3">៣៦. ឧបករណ៍ដែលត្រូវបានពិនិត្យដោយអនុលោមតាមកថាខណ្ឌ (ង) នៃឧបសម្ព័ន្ធ(ខ)</td><td>បាទ/ចាស</td><td>ទេ</td><td colspan="2">យោបល់</td></tr>
<tr><td colspan="7">៣៧. ការរកឃើញដោយមន្ត្រីអធិការកិច្ច</td></tr>
<tr><td colspan="7"></td></tr>
<tr><td colspan="7">៣៨. ការបំពានជាក់ស្តែងបានកត់ត្រាទុករួមមានសេចក្តីយោងទៅតាមលិខិតុបករណ៍ពាក់ព័ន្ធ</td></tr>
<tr><td colspan="7"></td></tr>
<tr><td colspan="7">៣៩. យោបល់របស់មេបញ្ជាការនាវា</td></tr>
<tr><td colspan="7"></td></tr>
<tr><td colspan="7">៤០. សកម្មភាពដែលបានចាត់វិធានការ</td></tr>
<tr><td colspan="7"></td></tr>
<tr><td colspan="7">៤១. ហត្ថលេខារបស់មេបញ្ជាការនាវា</td></tr>
<tr><td colspan="7"></td></tr>
<tr><td colspan="7">៤២. ហត្ថលេខារបស់អធិការ</td></tr>
<tr><td colspan="7"></td></tr>
</table>

## ឧបសម្ព័ន្ធ ឃ. ប្រព័ន្ធព័ត៌មានស្ដីពីទិន្នន័យការរដ្ឋម្ចាស់កំពង់ផែ

ក្នុងការអនុវត្តកិច្ចព្រមព្រៀងនេះភាគីនីមួយៗត្រូវ៖

(ក) ស្វះស្វែងបង្កើតទំនាក់ទំនងតាមប្រព័ន្ធកុំព្យូទ័រ ដោយអនុលោមតាមមាត្រា ១៦

(ខ) តាមលទ្ធភាពដែលអាចធ្វើទៅបានបង្កើតគេហទំព័រដើម្បីផ្សព្វផ្សាយបញ្ជីកំពង់ផែ ដែលបានកំណត់ ដោយអនុលោមតាមមាត្រា៧និងសកម្មភាពដែលត្រូវបានអនុវត្តដោយអនុលោមតាមបទប្បញ្ញត្តិពាក់ព័ន្ធនានានៃកិច្ចព្រមព្រៀងនេះ

(គ) តាមលទ្ធភាពធំធេងបំផុតដែលអាចធ្វើទៅបានកំណត់អត្តសញ្ញាណរបាយការណ៍អធិការកិច្ចនីមួយៗ ដោយចុះលេខយោងតែមួយគត់ ដែលចាប់ផ្ដើមពីលេខកូដ៣ខ្ទង់នៃរដ្ឋម្ចាស់កំពង់ផែ និងកំណត់អត្តសញ្ញាណរបស់ទីភ្នាក់ងារដែលចេញឯកសារ

(ឃ) តាមលទ្ធភាពដែលអាចធ្វើទៅបាន ប្រើប្រព័ន្ធលេខកូដអន្តរជាតិដូចក្នុងឧបសម្ព័ន្ធ "ក" និង "គ" ព្រមទាំងបកប្រែប្រព័ន្ធលេខកូដណាមួយផ្សេងទៀតទៅជាប្រព័ន្ធលេខកូដអន្តរជាតិ។

ប្រទេស/តំបន់ដែនដី៖ ISO-៣១៦៦-កូដប្រទេស៣ខ្ទង់

ប្រភេទត្រី៖ ASFIS កូដ៣ខ្ទង់ (ត្រូវបានស្គាល់ថាជាលេខកូដ៣ខ្ទង់របស់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ)

ប្រភេទនាវា៖ កូដ ISSCFV (ត្រូវបានស្គាល់ថាជាលេខកូដរបស់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ)

ប្រភេទឧបករណ៍៖ កូដ ISSCFG (ត្រូវបានស្គាល់ថាជាលេខកូដរបស់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ)

## ឧបសម្ព័ន្ធ ខ. គោលការណ៍ណែនាំសម្រាប់ការបណ្តុះបណ្តាលអធិការ

សមាសធាតុនៃកម្មវិធីបណ្តុះបណ្តាល សម្រាប់អធិការនៃរដ្ឋម្ចាស់កំពង់ផែ គួរតែរួមបញ្ចូលជំនាញយ៉ាងតិចដូចខាងក្រោម៖

១. ក្រមសីលធម៌។

២. បញ្ហាសុខភាព សុវត្ថិភាព និងសន្តិសុខ។

៣. ច្បាប់ និងបទប្បញ្ញត្តិគត្តិយុត្តិថ្នាក់ជាតិជាធរមាន ដែនសម្ថកិច្ច និងវិធានការគ្រប់គ្រង និងអភិរក្សនានារបស់ RFMOs និងច្បាប់អន្តរជាតិជាធរមាន។

៤. ការប្រមូល វាយតម្លៃ និងថែរក្សាភស្តុតាង។

៥. នីតិវិធីត្រួតពិនិត្យទូទៅ ដូចជាការសរសេររបាយការណ៍ និងបច្ចេកទេសធ្វើសំភាសន៍។

៦. ការវិភាគព័ត៌មាន ដូចជាសៀវភៅកំណត់ត្រា ឯកសារអេឡិចត្រូនិច និងប្រវត្តិនាវា (ឈ្មោះម្ចាស់នាវា និងរដ្ឋម្ចាស់ទង់ជាតិ) ដែលត្រូវមានដើម្បីវាយតម្លៃព័ត៌មានដែលផ្តល់ដោយមេបញ្ជាការនាវា។

៧. ការឡើងនិងការធ្វើអធិការកិច្ចលើនាវា រួមបញ្ចូលទាំងការធ្វើអធិការកិច្ច និងការគណនាបរិមាណផ្ទុករបស់នាវា។

៨. ការផ្ទៀងផ្ទាត់ និងសុពលភាពព័ត៌មានដែលទាក់ទងនឹងការចូលចត ការផ្ទេរទំនិញ ការកែច្នៃ និងផលនេសាទដែលនៅសល់នៅលើនាវា ដោយរួមបញ្ចូលទាំងការប្រើកត្តាបម្លែងតាមប្រភេទ និងផលិតផលត្រី។

៩. អត្តសញ្ញាកម្មប្រភេទត្រី និងវាស់ប្រវែង និងប៉ារ៉ាម៉ែត្រជីវសាស្ត្រផ្សេងទៀត។

១០. អត្តសញ្ញាណកម្មនាវា និងឧបករណ៍ និងបច្ចេកទេសសម្រាប់ត្រួតពិនិត្យ និងការវាស់វែងឧបករណ៍។

១១. ការភ្ជាប់ប្រព័ន្ធបរិក្ខារជំណើរការប្រព័ន្ធតាមដាននាវា (VMS) និងការតាមដាននាវាដោយប្រើប្រព័ន្ធអេឡិចត្រូនិច

១២. សកម្មភាពដែលត្រូវអនុវត្តក្រោយពីការធ្វើអធិការកិច្ច។

ឧបសម្ព័ន្ធច.	ព្រះរាជក្រមប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃកិច្ចព្រមព្រៀងស្តីពីវិធានការរដ្ឋម្ចាស់កំពង់ផែ ដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានការអនុញ្ញាត និងគ្មានរបាយការណ៍

# ព្រះរាជក្រម

នស/រកម/០៧១៩/០១០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហានាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃកិច្ចព្រមព្រៀងស្តីពីវិធានការរដ្ឋម្ចាស់កំពង់ផែ ដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៩ នាសម័យប្រជុំរដ្ឋសភា លើកទី២ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៩ នាសម័យប្រជុំពេញអង្គលើកទី៣ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅៈ

# ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃកិច្ចព្រមព្រៀងស្តីពីវិធានការរដ្ឋម្ចាស់កំពង់ផែ ដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត

**មាត្រា១.-**

អនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃកិច្ចព្រមព្រៀងស្តីពីវិធានការរដ្ឋម្ចាស់កំពង់ផែ ដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ដែលបានអនុម័តដោយសន្និសីទអង្គការស្បៀងនិងកសិកម្ម នៃសហប្រជាជាតិ នាថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៩ នៅរដ្ឋធានីរ៉ូម នៃសាធារណរដ្ឋអ៊ីតាលី ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ។

**មាត្រា២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តពល់នីតិវិធីដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ។

**មាត្រា៣.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃព្រហស្បតិ៍ ៩កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០១៩

នស/រកម.០៧១៩.០១០

នរោត្តមសីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រី ប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

Food and Agriculture Organization of the United Nations

រៀបចំបកប្រែពីច្បាប់ដើមរបស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ
ដោយរដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ការបោះពុម្ពផ្សាយនេះ ត្រូវបានផលិតឡើង
ដោយមានការគាំទ្រផ្នែកហិរញ្ញវត្ថុពីសហភាពអឺរ៉ុប។
ខ្លឹមសារជាការទទួលខុសត្រូវតែមួយគត់របស់ រដ្ឋបាលជលផល
ហើយមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុបទេ។